**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ
# និង
# ជនបរទេសនៅប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា.**កែ ស៊ីនស្រីមិច**
កញ្ញា.**រស់ រ៉ាវី**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ីង គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ក. **កែ ស៊ីនស្រីមិច** និងក.**រស់ រ៉ាវី** ជានិស្សិតបរិញ្ញាបត្រផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៥-២០១៩។ ក្នុងនាមពួកខ្ញុំជានិស្សិតជំនាន់ក្រោយដែលជាទំពាំងស្នងឬស្សី និងជាសសរទ្រូងនៃប្រទេសជាតិ យើងខ្ញុំបានស្រាវជ្រាវ និងសរសេរជាសារណា ដើម្បីការពារក្នុងការបញ្ចប់ឆ្នាំសិក្សា ក្រោមប្រធានបទស្តីពី "**ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា**"

នាងខ្ញុំទាំងពីរសូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះ

- លោកឪពុក **កែ សុគន្ធា** និងអ្នកម្តាយ **ឡាត់ តុល**
- លោកឪពុក **រស់ អួន** និងអ្នកម្តាយ **ចាន់ ហ៊ុន**

យើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណដល់អ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំចាប់តាំងពីថ្ងៃចាប់កំណើត រហូតដល់ពួកយើងខ្ញុំធំធាត់លូតលាស់ឡើង និងទទួលបានការសិក្សារហូតដល់បានបញ្ចប់បរិញ្ញាបត្រនេះក៏ព្រោះតែមានការជ្រោមជ្រែង និងឧបត្ថម្ភពីលោកទាំងពីរ ទាំងកំលាំងកាយ និងកំលាំងចិត្ត។ គុណូបការៈ និងព្រហ្មវិហារធម៌អ្នកមានគុណចំពោះយើងខ្ញុំពិតជាធំធេងរកអ្វីប្រៀបផ្ទឹមថ្មីបានឡើយ ទាំងនេះហើយទើបធ្វើឲ្យកូនមិនអាចចំភ្លេចនូវគុណូបការៈរបស់លោកទាំងពីរបានឡើយ កូនសូមធ្វើការសន្យាថាកូននឹងចង់ចាំរាល់ទង្វើរបស់លោកទាំងពីរជារៀងរហូតទៅ។

នាងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណផងដែរ ចំពោះ លោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការពន្យល់ នែនាំ ផ្តល់ ដំបូន្មានក៏ដូចជាកែតម្រូវរាល់កំហុសខុសឆ្គង និងភាពខ្វះខាតដែលកើតមានពេលរៀបចំចងក្រងនៅសារណានេះ។ បើមិនមានវត្តមានរបស់លោកគ្រូក្នុងការដឹកនាំទេ នោះសារណានេះក៏មិនអាចបញ្ចប់ទៅដោយរលូតបែបនេះឡើយ។ បន្តទៅនេះនាងខ្ញុំក៏សូមអរគុណទៅដល់សាស្ត្រាចារ្យទាំងអស់ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ដែលបានចែករំលែកនូវចំណេះដឹង ក៏ដូចជាបទពិសោធជាច្រើនដល់រូបនាងខ្ញុំ ចំនេះដឹងទាំងនេះហើយ គឺជាយាន្តនៃប្រភពគំនិតដែលអាចឲ្យនាងខ្ញុំតាក់តែងនូវសារណានេះបានដោយជោគជ័យ។

សូមថ្លែងអំណរគុណជូនចំពោះ លោកតា លោកយាយ អ៊ុំប្រុស អ៊ុំស្រី ពូមីង បងប្អូន ញាតិមិត្តជិតឆ្ងាយទាំងអស់ ដែលបានផ្តល់កំលាំងចិត្តដល់យើងទាំងពីរក្នុងការសរសេរតាក់តែងនូវសារណានេះ។

ជាអាវសាន យើងខ្ញុំសូមគោរពអរគុណជូនពរ និងលើកហត្ថប្រួងសួងដល់អ្នកមានគុណ លោកតា លោកយាយ អ៊ុំប្រុស អ៊ុំស្រី ពូមីង លោកគ្រូ អ្នកគ្រូ បងប្អូន ញាតិមិត្តជិតឆ្ងាយ ឲ្យជួបតែពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងជួបប្រកបតែសេចក្តីសុខចម្រើនជាដរាបទៅ។

# អារម្ភកថា

អស់រយៈពេលបួនឆ្នាំមកហើយដែលយើងខ្ញុំទាំងពីរបានសិក្សានូវមុខវិជ្ជានីតិសាស្ត្រនេះនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។ យើងខ្ញុំទាំងពីរ បានសិក្សាស្រាវជ្រាវទាក់ទងនឹងបញ្ហាច្បាប់នៅក្នុងប្រទេសកម្ពុជាយើងជាច្រើន ដែលប្រជាពលរដ្ឋខ្មែរយើងកម្ពុជាជួបប្រទះនាពេលបច្ចុប្បន្ននេះ។ តាមរយៈការស្រាវជ្រាវកន្លងមកយើងខ្ញុំទាំងពីរបានសង្កេតឃើញថាប្រជាពលរដ្ឋខ្មែរយើងនៅមានភាពស្រពិចស្រពិលនៃនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ លើសពីនេះទៀតសោតអ្វីដែលជាបញ្ហាគួរឲ្យបារម្ភទៀតគឺការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។ ថ្វីត្បិតតែការរៀបអាពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសមានភាពប្រហាក់ប្រហាក់ប្រហែលគ្នាក្តី តែវានាំមកនូវបញ្ហាចោទមួយចំនួនដែលពលរដ្ឋខ្មែរគួរយល់ដឹង។

ក្នុងនាមយើងខ្ញុំទាំងពីរជាទំពាំងស្នងឬស្សី និងចង់បន្សល់ទុកនូវស្នាដៃក៏ដូចជាចូលរួមរំលែកក្នុងការជួយសង្គមយើងទាំងពីរបានស្រាវជ្រាវសារណាមួយក្រោមប្រធានបទស្តីអំពី "**ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា**" មកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សានេះ។ យើងខ្ញុំទាំងពីរសង្ឃឹមយ៉ាងមុតមាំថាអត្ថបទសារណានេះនឹងអាចជួយដល់បងប្អូនមិនថាជនជាតិខ្មែរ ឬជាតិសាសន៍ដទៃក្នុងការយល់ដឹងអំពីការរៀបអាពាហ៍ពិពាហ៍ថាធ្វើយ៉ាងណាទើបត្រឹមត្រូវតាមនិតិវិធីច្បាប់។

ក្នុងកំឡុងពេលនៃការស្រាវជ្រាវនេះ យើងខ្ញុំបានសង្កេតឃើញថានាងខ្ញុំបានទទួលនូវអ្វីៗដែលថ្មីជាច្រើន និងអ្វីៗមួយចំនួនដែលពួកនាងខ្ញុំមិនបានដឹងពីមុនមក។ ហេតុនេះហើយទើបយើងខ្ញុំជឿជាក់ថា អត្ថបទស្រាវជ្រាវនេះនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់មិត្តអ្នកអានទាំងអស់ក្នុងការយល់ដឹងបន្ថែមពីចំណុចមួយចំនួន និងបំពេញនូវចន្លោះខ្វះខាតដែលទាក់ទងនឹងអាពាហ៍ពិពាហ៍នេះ។

ថ្វីត្បិតតែយើងទាំងពីរបានខិតខំព្យាយាមក្នុងការស្រាវជ្រាវអត្ថបទនេះយ៉ាងណាក្តី តែពួកយើងខ្ញុំទាំងពីរជឿជាក់ថា គង់នឹងមានភាពខ្វះខាតដោយអចេតនាណាមួយដែលកើតមានក្នុងអត្ថបទនេះ។ ជាចុងបញ្ចប់នេះយើងខ្ញុំសូមអភ័យទោសរាល់កំហុសខ្វះខាតដែលកើតមានក្នុងអត្ថបទសារណានេះ ក៏សូមអរគុណដល់បងប្អូនអ្នកអានទាំងឡាយដែលបានយកចិត្តទុកដាក់ក្នុងការអាននូវអត្ថបទសារណានេះ។

**សេចក្តីផ្តើម** ១

## ជំពូកទី១
## វិធានជាមូលដ្ឋានក្នុងការបង្កើតអាពាហ៍ពិពាហ៍

**១.១ ៖ គោលការណ៍គ្រឹះនៃការបង្កើតអាពាហ៍ពិពាហ៍** ២
១.១.១ ៖ គោលការណ៍ស្ម័គ្រចិត្ត ២
១.១.២ ៖ គោលការណ៍ផ្ទុយគ្នានៃភេទ ២
១.១.៣ ៖ គោលការណ៍ភាគី ( ពលរដ្ឋខ្មែរ និងជនបរទេស) ៣
១.១.៤ ៖ គោលការណ៍ប្រព្រឹត្តទៅតាមច្បាប់ ៤
១.១.៥ ៖ គោលការណ៍នៅលីវ ពោះម៉ាយ ឬមេម៉ាយ ៤
១.១.៦ ៖ គោលការណ៍ស្របច្បាប់នៃអាយុរបស់ភាគី ៥
១.១.៧ ៖ គោលការណ៍អនុញ្ញាតពីឪពុកម្តាយ ឬតុលាការ ៦
១.១.៨ ៖ គោលការណ៍ហាមឃាត់មិនអោយមានការរៀបអាពាហ៍ពិពាហ៍ ៧

## ជំពូកទី២
## បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

**២.១ កំជាប់ពាក្យ ឬពិធីលើកស្លា ឬពិធីភ្ជាប់ពាក្យ** ១០
២.១.១ ៖ និយមន័យ ១០
២.១.២ ៖ លក្ខខណ្ឌនៃការបង្កើត ១០
២.១.៣ ៖ ការសងជំនូន ១១
២.១.៤ ៖ អាជ្ញាយុកាលនៃការដាក់ពាក្យបណ្តឹង ១១

**២.២ ៖ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស** ១២
២.២.១ ៖ ការបំពេញបែបបទ ១២
២.២.២ ៖ នីតិវិធីនៅក្រសួងការបរទេស ១៣
២.២.៣ ៖ នីតិវិធីនៅក្នុងក្រសួងមហាផ្ទៃ ១៤
២.២.៤ ៖ នីតិវីធីនៅមន្ត្រីអគ្រានុកូលដ្ឋានកម្ពុជា ១៤

**២.៣ ៖ ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលត្រូវបានកម្រិតសមត្ថភាព** ១៥

២.៣.១ ៖ ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនចាប់ពី១៦ ឆ្នាំ ________ ១៦
២.៣.២ ៖ ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ ________ ១៦
២.៣.៣ ៖ ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ ________ ១៧

**២.៤ ៖ ការចាត់ទុកប្ដីប្រពន្ធដែលគ្មានអនុភាពតាមផ្លូវច្បាប់ ________ ១៧**

២.៤.១ ៖ ការរស់នៅជាមួយគ្នាជាអនីតិសង្វាសជន ________ ១៧
២.៤.២ ៖ ការរស់នៅជាមួយគ្នាតាមប្រពៃណីតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ១៧

**២.៥ ៖ ការបច់កប្រែមសេវារដ្ឋបាល ________ ១៨**

២.៥.១ ៖ នៅក្រសួងការបរទេស ________ ១៨
២.៥.២ ៖ នៅក្រសួងមហាផ្ទៃ ________ ១៨
២.៥.៣ ៖ នៅរដ្ឋបាល ឃុំ សង្កាត់ ________ ១៩

**២.៦ ៖ ទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ________ ១៩**

២.៦.១ ៖ មោឃភាព ________ ១៩
២.៦.២ ៖ ការលុបចោលអាពាហ៍ពិពាហ៍ ________ ២០

**២.៧ ៖ អានុភាពនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ________ ២០**

២.៧.១ ៖ ចំពោះទំនាក់ទំនងបុគ្គល ________ ២០
២.៧.១.១ ៖ ការបង្កើតទំនាក់ទំនងញាតិពន្ធ ________ ២០
២.៧.១.២ ៖ ការបង្កើតស្ដុំកូនពេញលេញ ________ ២១
២.៧.១.៣ ៖ ការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ ________ ២១
២.៧.១.៤ ៖ ការទទួលបាននីតិភាព ________ ២២
២.៧.១.៥ ៖ ការទទួលបានឋានៈជាអ្នកមានអំណាចមេបា ________ ២២
២.៧.២ ៖ ចំពោះកាតព្វកិច្ចកំណត់ដោយក្រមរដ្ឋប្បវេណី ________ ២២
២.៧.២.១ ៖ ករណីយកិច្ចរួមរស់ សហការ និងសង្គ្រោះគ្នា ________ ២២
២.៧.២.២ ៖ សេរីភាពក្នុងការចូលរួមសកម្មភាពសង្គម និងជ្រើសរើសវិជ្ជាជីវៈ__ ២៣
២.៧.២.៣ ៖ ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ________ ២៣

២.៧.២.៤ ៖ ការទទួលខុសត្រូវដោយសាមគ្គីភាព ____________________ ២៣
២.៧.៣ ៖ ប្រព័ន្ធទ្រព្យសម្បត្តិ ប្តី ប្រពន្ធ ____________________ ២៤
២.៧.៣.១ ៖ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ____________________ ២៤
២.៧.៤ ៖ អានុភាពចំពោះអំពើ ឬសកម្មភាពដែលត្រូវលើកលែង និងការហាមឃាត់ដោយច្បាប់បញ្ញត្តិខ្លះនៃក្រមរដ្ឋប្បវេណី ____________________ ២៥
២.៧.៤.១ ៖ ការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ____________________ ២៦
២.៧.៤.២ ៖ ការហាមឃាត់ដោយច្បាប់ និងការទទួលខុសត្រូវព្រហ្មទណ្ឌ______ ២៦
២.៧.៥ ៖ លក្ខខណ្ឌពិសេសដែលទទួលបាន ____________________ ២៧

## ជំពូកទី៣

## ការលែងលះ និងអនុភាពនៃការលែងលះរវាងពលរដ្ឋខ្មែរ និងជនបរទេស

**៣.១ ៖ អត្ថន័យនៃការលែងលះ** ____________________ ២៨
៣.១.១ ៖ ការលែងលះតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ _____ ២៨
៣.១.២ ៖ អត្ថន័យនៃការលែងលះតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧____________ ២៩
**៣.២ ៖ ប្រភេទនៃការលែងលះ** ____________________ ២៩
៣.២.១ ៖ ការលែងលះដោយការព្រមព្រៀង ____________________ ២៩
៣.២.២ ៖ ការលែងលះដោយមិនមានការព្រមព្រៀង ____________________ ៣០
**៣.៣ ៖ នីតិវិធីក្នុងការលែងលះ**____________________ ៣២
៣.៣.១ ៖ ជនដែលមានសិទ្ធិក្នុងការលែងលះ ____________________ ៣២
៣.៣.២ ៖ សមត្ថកិច្ចដែលមានសិទ្ធិក្នុងការផ្សះផ្សា និងលែងលះ______________ ៣២
ក . សមត្ថកិច្ចនៅអាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់)_______________ ៣២
ខ. សមត្ថកិច្ចនៅតុលាការ (សាលាដំបូង រាជធានី ខេត្ត) ________________ ៣៣
៣.៣.៣ ៖ ចំណាត់ការក្នុងការលែងលះ ____________________ ៣៣
ក. នីតិវិធីត្រៀមទាញហេតុផលតាមពាក្យបណ្តឹង និងពាក្យសុំ_____________ ៣៤
៣.៣.៤ ៖ ការប្រកាសសេចក្តីសម្រេច ____________________ ៣៦
**៤.១ ៖ អានុភាពក្រោយការលែងលះចំពោះសហព័ទ្ធ**__________________ ៣៧

៤.១.១ ៖ ការផ្តាច់ចំណងសហព័ទ្ធ ______________________________ ៣៧
៤.១.២ ៖ ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ ______________________________ ៣៧
៤.១.៣ ៖ ការទទួលបានអាហារកិច្ច ______________________________ ៣៨
**៤.២ ៖ អានុភាពចំពោះការបែងចែកទ្រព្យសម្បត្តិ** ______________________________ ៣៩
៤.២.១ ៖ ការបែងចែកទ្រព្យតាមកិច្ចសន្យា ______________________________ ៣៩
៤.២.២ ៖ ការបែងចែកទ្រព្យតាមការព្រមព្រៀងរបស់ភាគី ______________________________ ៣៩
៤.២.៣ ៖ ការបែងចែកទ្រព្យដោយតុលាការ ______________________________ ៣៩
**៤.៣ ៖ អានុភាពចំពោះទ្រព្យដែលជាបំណុល** ______________________________ ៤០
៤.៣.១ ៖ បំណុលផ្ទាល់ខ្លួន ______________________________ ៤០
៤.៣.២ ៖ បំណុលរួម ______________________________ ៤១
**៤.៤ ៖ អានុភាពចំពោះការគ្រប់គ្រង និងបែងចែកកូន** ______________________________ ៤១
**សេចក្តីសន្និដ្ឋាន** ______________________________ ៤២
**អនុសាសន៍** ______________________________ ៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងអភិវឌ្ឍន៍ និងមានអ្នកវិនិយោគដែលជាជនបរទេសជាច្រើនបានមកវិនិយោគនៅក្នុងប្រទេសកម្ពុជា ហេតុនេះហើយទើបទំនាក់ទំនងស្នេហារវាងពលរដ្ឋខ្មែរ និងជនបរទេសមានការកើនឡើងគួរឲ្យកត់សម្គាល់ បញ្ហាគឺនៅត្រង់ថាតើការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងពលរដ្ឋខ្មែរធ្វើយ៉ាងណាទើបអាចចាត់ទុកថាមានអានុភាពតាមផ្លូវច្បាប់ ? នៅពេលនិយាយដល់ការរៀបអាពាហ៍ពិពាហ៍ប្រជាជនខ្មែរភាគច្រើនតែងតែនឹកឃើញដល់ការប្រារព្ធពិធីតាមបែបប្រពៃណីទំនៀមទំលាប់ខ្មែររវាងបុរស និងនារីដែលស្ម័គ្រចិត្តរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធជាជាងនឹកឃើញដល់ការចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលគោរពខ្ជាប់ខ្ជួនទៅតាមនីតិវិធីច្បាប់។ រីឯជនបរទេសជាពិសេសគឺជនបរទេសដែលនៅបណ្ដាប្រទេសនៃភាគខាងលិច គឺមិនសូវចាត់ទុកការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ គឺមានភាពសំខាន់ឡើយ ព្រោះហេតុថាពួកគេចូលចិត្តរស់នៅជាមួយគ្នាតាមបែបអនីតិសង្វាស ព្រោះវាមានភាពងាយស្រួលមិនចាំបាច់គោរពនូវនីតិវិធីផ្សេងៗ នាំឲ្យមានភាពស្មុគស្មាញ។ ហេតុនេះស្ដែងឲ្យឃើញថាការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ គឺនៅតែជាបញ្ហាដែលយើងគ្រប់គ្នាត្រូវព្រួយបារម្ភ ព្រោះនៅមានប្រជាជនមួយចំនួននៅមិនទាន់មានការយល់ដឹងច្បាស់អំពីផលអវិជ្ជមានដែលកើតឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍ដែលមិនចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមនីតិវិធីច្បាប់ឡើយ។ អាពាហ៍ពិពាហ៍ដែលត្រូវបានចាត់ទុកថាជាអាពាហ៍ពិពាហ៍ដែលស្របទៅតាមច្បាប់លុះត្រាតែអាពាហ៍ពិពាហ៍មួយនោះ គោរពទៅលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។ លក្ខខណ្ឌគ្រឹះរួមមាន៖ ការស្ម័គ្រចិត្ត គោលការណ៍នៃភេទផ្ទុយគ្នា គោលការណ៍ភាគី គោលការណ៍ប្រព្រឹត្តទៅតាមច្បាប់ គោលការណ៍នៅលីវ ពោះម៉ាយ រឺមេម៉ាយ លក្ខខណ្ឌជាដើម ។ រីឯលក្ខខណ្ឌទម្រង់គឺទាក់ទងនឹងនីតិវិធីច្បាប់ រួមមានការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការបំពេញបែបបទទៅក្រសួងការបរទេស នីតិវិធីក្រសួងមហាផ្ទៃ និងនីតិវិធីនៅមន្ត្រីអត្រានុកូលដ្ឋានជាដើម។ ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅព្រះរាជាណាចក្រកម្ពុជា គឺពុំមានភាពខុសគ្នាខ្លាំងទេអំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ តួយ៉ាងគឺគ្រាន់តែមាននីតិវិធីខុសគ្នាតែបន្តិចបន្តួចតែប៉ុណ្ណោះ។

ដូចនេះ ដើម្បីឲ្យជ្រាបច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍មួយស្របច្បាប់រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅប្រទេសកម្ពុជា យើងខ្ញុំទាំងពីរបានបែងចែកអត្ថបទសារណានេះជាបីជំពូកធំៗគឺ៖

ជំពូកទី១៖ វិធានជាមូលដ្ឋាននៃការបង្កើតអាពាហ៍ពិពាហ៍

ជំពូកទី២៖បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ជំពូកទី៣៖ ការលែងលះ និងអនុភាពនៃការលែងលះរវាងពលរដ្ឋខ្មែរ និងជនបរទេស

# ជំពូកទី១

# វិធានជាមូលដ្ឋានក្នុងការបង្កើតអាពាហ៍ពិពាហ៍

# ជំពូកទី១
# វិធានជាមូលដ្ឋានក្នុងការបង្កើតអាពាហ៍ពិពាហ៍

## ១.១ ៖ គោលការណ៍គ្រឹះនៃការបង្កើតអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិករវាងបុរស និងនារីដែលសន្យាថានឹងរួមរស់ជាមួយគ្នាមិនត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះទេតែគឺអស់មួយជីវិត។ អាពាហ៍ពិពាហ៍មានភាពសំខាន់ណាស់នៅក្នុងជីវិតមនុស្សម្នាក់ៗ ហេតុនេះហើយទើបច្បាប់បានចែង និងកំណត់យ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍មិនអាចបង្កើតទៅតាមអំពើចិត្តរបស់គូភាគីបានឡើយ ពោលគឺត្រូវគោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមគោលការណ៍ច្បាប់ ដូចដែលមានចែងក្នុងបទដ្ឋានគតិយុត្តនៃប្រទេសកម្ពុជា ។

គោលការណ៍ទាំងនោះរួមមាន៖

### ១.១.១ ៖ គោលការណ៍ស្ម័គ្រចិត្ត

អាពាហ៍ពិពាហ៍មួយដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការស្មគ្រ័ចិត្តរវាងគូភាគីជាមុនសិន។ ដោយផ្អែកតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៥ បានចែងថា "អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្មគ្រ័ចិត្តប្តីមួយប្រពន្ធមួយ"[1]។ ដូចគ្នានេះដែរ ដោយយោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ត្រង់មាត្រា២៣ ចំនុចទី៣ បានចែងថា "គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រមដោយសេរី និងពេញលេញពីអនាគតប្តី ប្រពន្ធឡើយ" [2] ។ ហេតុនេះសបញ្ជាក់អោយឃើញថាការបង្ខិតបង្ខំទៅលើភាគីណាមួយអោយរៀបការដោយមិនចេញពីឆន្ទៈរបស់បុគ្គលនោះ គឺវាផ្ទុយទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិទាំងស្រុង។

### ១.១.២ ៖ គោលការណ៍ផ្ទុយគ្នានៃភេទ

តាមទំនៀមទំលាប់ប្រពៃណីខ្មែរពីបុរាណមកយើងសង្កេតឃើញថា ការរៀបអាពាហ៍ពិពាហ៍គឺប្រព្រឹត្តបានតែរវាងបុរសនិងនារីតែប៉ុណ្ណោះ ព្រោះគេជឿជាក់ថាអាពាហ៍ពិពាហ៍ដែលកើតឡើងរវាងភេទដូចគ្នា គឺវាផ្ទុយនឹងក្រឹត្យក្រមធម្មជាតិ និងមិនអាចបង្កើតកូនដើម្បីបន្តពូជពង្សវង្សត្រកូល

1 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៤៥។

2 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម, តុលា ២០០៩, មាត្រា២៣ ចំណុចទី៣។

បានឡើយ។ នាំឲ្យនៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ត្រង់មាត្រា៣ បានចែងថា "អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន"[3]។ រីឯមាត្រា៦ ក្នុងច្បាប់ដដែលបានបញ្ញត្តិថា "មិនអាចរៀបអាពាហ៍ពិពាហ៍រវាងភេទដូចគ្នា"[4] ក៏ពិតមែន ប៉ុន្តែក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ជាក់ត្រង់មាត្រា ៩៤៨ ដោយបញ្ញតិថា "បុរស និងនារីដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ"[5]។ ចំពោះការប្រើប្រាស់ពាក្យ ក្នុងក្រមនេះ គឺបង្កប់អត្ថន័យស្តែងឲ្យឃើញថា មានតែបុរស និងនារីតែប៉ុណ្ណោះទើបអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន និងមានការទទួលស្គាល់តាមផ្លូវច្បាប់។ យើងសង្កេតឃើញថាការរៀបអាពាហ៍ពិពាហ៍ជាមួយភេទដូចគ្នា គឺមិនអាចប្រព្រឹត្តទៅបានទេទាំងនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន និងក្នុងច្បាប់ ពីព្រោះមានតែបុរស និងនារីទេ ដែលច្បាប់ទទួលស្គាល់ និងសង្គមខ្មែរទទួលស្គាល់ ប៉ុន្តែនៅតាមបណ្តាប្រទេសមួយចំនួន មានការទទួលស្គាល់ឲ្យមានការរៀបអាពាហ៍ពិពាហ៍រវាងភេទដូចគ្នា តែច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន គឺមិនទាន់ទទួលស្គាល់នៅឡើយទេ យ៉ាងណាមិញការរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានលុះត្រាតែជននោះមានភេទផ្ទុយគ្នា (បុរស និងនារី)។

### **១.១.៣៖ គោលការណ៍ភាគី ( ពលរដ្ឋខ្មែរ និងជនបរទេស)**

ផ្អែកលើប្រធានបទខាងលើ គឺផ្តោតតែទៅលើការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅព្រះរាជាណាចក្រកម្ពុជា ដូច្នេះហើយ ភាគីដែលអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែ ម្ខាងជាពលរដ្ឋខ្មែរ និងម្ខាងជាជនបរទេស។ ពាក្យថាពលរដ្ឋខ្មែរ គឺសំដៅទៅលើ "ជនណាដែលមានសញ្ជាតិខ្មែរ"[6]។ ជនបរទេស គឺសំដៅទៅលើ "ជនណាដែលគ្មានសញ្ជាតិខ្មែរដោយគ្មានរើសអើងទោះបីជាជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ"[7]។ សញ្ជាតិគឺសំដៅទៅលើទំនាក់ទំនងផ្លូវច្បាប់រវាងបុគ្គលជាមួយនឹងរដ្ឋដើម្បីទទួលបានសិទ្ធិរស់នៅដោយស្របច្បាប់ក្នុងប្រទេសណាមួយ។ លើសពីនេះទៅទៀត "ជនបរទេស បែងចែកជាបីប្រភេទ គឺ ជនបរទេសអន្តោប្រវេសន៍ ជនបរទេសមិនមែនអន្តោប្រវេសន៍ និងជនបរទេសអន្តោប្រវេសន៍

3 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៣។

4 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៦។

5 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨។

6 ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/១០៩៦/៣០,២០ សីហា ១៩៩៦, មាត្រា២ កថាខណ្ឌ១។

7 ច្បាប់ស្តីពីអន្តោប្រវេសន៍, ២៦ សីហា ១៩៩៤, មាត្រា២។

ជាអ្នកវិនិយោគឯកជន"[8]។ គ្រប់ប្រភេទជនបរទេសទាំងអស់ខាងលើ ដែលបានមករស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា គឺអាចមានសិទ្ធិស្នើសុំរៀបអាពាហ៍ពិពាហ៍បាន ដោយផ្អែកតាមលក្ខខណ្ឌដែលច្បាប់បាន កំណត់។ ហេតុនេះ ជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរចាំបាច់ត្រូវតែជាជនបរទេសដែលមានការទទួលស្គាល់ពីច្បាប់ និងមករស់នៅស្របតាមច្បាប់នៃប្រទេសកម្ពុជា។

### ១.១.៤៖ គោលការណ៍ប្រព្រឹត្តនៅតាមច្បាប់

នៅក្នុងប្រទេសនីមួយៗ តែងតែមានច្បាប់ដឹកនាំប្រទេសឲ្យមានសណ្ដាប់ធ្នាប់ និងមានរបៀបរៀបរយនៅក្នុងសង្គម រួមជាមួយគ្នាផងដែរ អាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាក៏ត្រូវបានកំណត់យ៉ាងជាក់លាក់ ដើម្បីជៀសវាងនូវបញ្ហាដែលអាចនឹងកើតមានឡើងនៅពេលក្រោយ។ ដូច្នេះហើយ ទើបតម្រូវឲ្យភាគីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ត្រូវគោរពទៅតាមលក្ខខណ្ឌមួយចំនួន ដូចជាលក្ខខណ្ឌគ្រឹះ ( ភេទ អាយុ ឆន្ទៈ សមត្ថភាព) និងលក្ខខណ្ឌទម្រង់ជាដើម។ យ៉ាងណាមិញ ការរៀបអាពាហ៍ពិពាហ៍ត្រូវបានកំណត់ក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ដូចនេះលុះត្រាតែ ភាគីទាំងសងខាងគោរពទៅតាមបទបញ្ញត្តិច្បាប់ដូចដែលបានរៀបរាប់ខាងលើទើបអាពាហ៍ពិពាហ៍នោះ ត្រូវបានគេចាត់ទុកថាមានអានុភាពតាមផ្លូវច្បាប់។ "អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយតាមរយៈការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន"[9]។

ដូច្នេះហើយ ប្រសិនបើគូភាគីមានបំណងចង់រៀបអាពាហ៍ពិពាហ៍ គឺតម្រូវឲ្យធ្វើតាមនីតិវិធីច្បាប់ និងគោរពតាមលក្ខខណ្ឌ ទើបមានសុពលភាពក្លាយជាសហព័ទ្ធនឹងគ្នា។

### ១.១.៥៖ គោលការណ៍នៅលីវ ពោះម៉ាយ ឬមេម៉ាយ

ភាពនៅលីវ ពោះម៉ាយ ឬមេម៉ាយជាកត្តាមួយយ៉ាងសំខាន់ដែលអាចបង្កើតបាននូវចំណងអាពាហ៍ពិពាហ៍ ពីព្រោះថា បើភាគីណាមួយមានចំណងអាពាហ៍ពិពាហ៍ដែលមិនទាន់រលាយនោះអាពាហ៍ពិពាហ៍ថ្មីមួយទៀតមិនអាចកើតបានទេ គឺវាផ្ទុយទៅនឹងច្បាប់ដែលបានកំណត់នូវគោលការណ៍ឯកពន្ធភាព "បុរស ត្រូវតែមានប្រពន្ធមួយ ឯស្ត្រីមានប្ដីតែមួយ"[10]។ ដូច្នេះ ប្រសិនបើជន

---

8 ច្បាប់ស្តីពីអន្តោប្រវេសន៍, ២៦ សីហា ១៩៩៤, មាត្រា៤។

9 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៥។

10 ច្បាប់ឯកពន្ធភាព,នស/រកម/១០០៦/០២៦,០១ កញ្ញា២០០៦,មាត្រា៣។

ដែលចង់រៀបអាពាហ៍ពិពាហ៍តម្រូវឲ្យមានសំបុត្របញ្ជាក់ពីភាពនៅលីវ ពោះម៉ាយ ឬមេម៉ាយ ពីមន្ត្រីអាត្រាកូលដ្ឋានជាមុនសិន។ បើយោងតាមវចនានុក្រមសម្តេចសង្ឃជួនណាតបានឲ្យនិយមន័យត្រង់ពាក្យ នៅលីវថា "ដែលមិនទាន់មានប្រពន្ធ ឬប្តីសោះនៅឡើយទេ" [11] ។ បើយោងតាមវចនានុក្រមសម្តេចសង្ឃជួនណាតដដែលបានឲ្យនិយមន័យពាក្យពោះម៉ាយ ឬមេម៉ាយ ថា "បុរស ឬនារី ដែលបានលែងលះគ្នា ឬបាត់បង់ចោល" [12] ។ ដូចនេះ បើជនដែលមិនទាន់មានចំណងអាពាហ៍ពិពាហ៍ពីមុនមកទេ គឺគ្រាន់តែបញ្ជាក់អំពីភាពនៅលីវគឺជាការស្រេច។ រីឯពោះម៉ាយ ឬមេម៉ាយមានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ម្តងទៀតដូចគ្នា ប្រសិនបើសាមីបានបញ្ជាក់សំបុត្រពោះម៉ាយ ឬមេម៉ាយនៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានរបស់ខ្លួន ដើម្បីបញ្ជាក់ថាខ្លួនបានផ្តាច់ទំនាក់ទំនងសហព័ទ្ធ និងទំនាក់ទំនងញាតិពីអតីតប្តី ឬប្រពន្ធមុនចប់សព្វគ្រប់ដូចនេះគាត់អាចមានសិទ្ធរៀបអាពាហ៍ពិពាហ៍ម្តងទៀតបាន។ការធ្វើបែបនេះដើម្បីការពារមិនឲ្យមានអាពាហ៍ពិពាហ៍ដែលជាន់លើគ្នា គឺសំដៅលើបុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍មួយដែលមិនទាន់រំលាយ តែបែជាមានបំណងចង់បង្កើតអាពាហ៍ថ្មីទៅវិញដែលជាហេតុនាំឲ្យមានការប៉ះពាល់ភាគីពាក់ព័ន្ធ។

### ១.១.៦ ៖ គោលការណ៍ស្របច្បាប់នៃអាយុរបស់ភាគី

ក្នុងការរៀបអាពាហ៍ពិពាហ៍អាយុ គឺជាចំនុចសំខាន់ដែលអាចឲ្យអាពាហ៍ពិពាហ៍នោះប្រព្រឹត្តបានតាមច្បាប់ ដោយឡែកនៅបណ្តាប្រទេសនីមួយៗមានការបែងចែកពីអាយុក្នុងការរៀបអាពាហ៍ពិពាហ៍ខុសៗគ្នាទៅតាមបរិបទនៃប្រទេសនីមួយៗ។ បើយើងក្រឡេកមកមើលប្រទេសកម្ពុជាវិញ ការរៀបអាពាហ៍ពិពាហ៍ក៏ត្រូវបានបញ្ញត្តិអំពីអាយុផងដែរ បើយោងតាមច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ ត្រង់មាត្រា៥ បានបញ្ញត្តិថា "អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយ២០ឆ្នាំឡើង និងនារីចាប់ពីអាយុ១៨ឆ្នាំឡើង ប៉ុន្តែក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់២០ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់១៨ឆ្នាំអាចរៀបអាពាហ៍ពិពាហ៍បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល" [13]។ ដោយតម្រូវតាមបរិបទសង្គមក៏មានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចូលមកដែលបានកំណត់ពីអាយុរបស់ភាគី ត្រង់មាត្រា៩៤៨ បានចែងថា "បុរស និងនារី បានដល់នីតិភាព ហើយភាគីម្ខាងទៀតជានីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នក

11 វចនានុក្រមសម្តេចសង្ឃជួនណាត

12 វចនានុក្រមសម្តេចសង្ឃជួនណាត

13 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៥។

អាណាព្យាបាលសម្រាប់អនីតិជននោះ”[14]។ ដូច្នេះ យើងឃើញភាពខុសគ្នារវាងច្បាប់ទាំងពីរ ដោយច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានចែងយ៉ាងច្បាស់អំពីអាយុរបស់បុរស២០ឆ្នាំ និងនារី១៨ឆ្នាំ ក្នុងករណីលើកលែងប្រសិនបើបុរសមិនទាន់ដល់អាយុ២០ឆ្នាំ និងនារីមិនទាន់ដល់អាយុ១៨ឆ្នាំ ប៉ុន្តែនារីនោះបានមានផ្ទៃពោះហើយមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលនោះភាគីអាចរៀបអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែក្រមរដ្ឋប្បវេណីវិញមិនបានចែងច្បាស់លាស់ថាបុរសមានអាយុប៉ុន្មាន ឬនារីមានអាយុប៉ុន្មានដែលអាចរៀបអាពាហ៍ពិពាហ៍បាននោះទេ តែក្នុងចំនោមភាគីម្ខាងបានដល់នីតិភាព គឺអាចរៀបអាពាហ៍ពិពាហ៍បានដោយភាគីម្ខាងមានអាយុ ១៨ឆ្នាំ (នីតិជន) និងម្ខាងទៀតមានអាយុ១៦ឡើងទៅ (អនីតិជន) ហើយមានអំណាចមេបា ឬ អាណាព្យាបាលជាការស្រេចមិនចាំបាច់ទាល់តែនារីមានផ្ទៃពោះដូចច្បាប់អាពាហ៍ពិពាហ៍នោះទេ។ លើសពីនេះទៅទៀតក្នុងករណីដែលភាគីខាងណាដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍តែភាគីនោះទទួលបាននូវអត្តាធិនភាព ដូចនេះសាមីខ្លួនមានសិទ្ធិសម្រេចការរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯងបាន ដោយមិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាលឡើយ ហេតុដូចនេះហើយអាយុ គឺជាកត្តាសំខាន់ដើម្បីឲ្យភាគីទាំងពីរអាចរៀបអាពាហ៍ពិពាហ៍បានទៅតាមផ្លូវច្បាប់។

### ១.១.៧៖ គោលការណ៍អនុញ្ញាតពីឪពុកម្តាយ ឬតុលាការ

រវាងនីតិជន និងនីតិជនមានបំណងចង់រៀបអាពាហ៍ពិពាហ៍ គឺមិនមែនជាបញ្ហាចោទសម្រាប់ពួកគាត់នោះទេ ពីព្រោះពួកគាត់បានដល់នីតិភាពដោយមិនតម្រូវឲ្យមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលរបស់ពួកគាត់ទេ ឲ្យតែមានឆន្ទៈយល់ព្រមរវាងភាគីជាការស្រេច គឺពួកគាត់អាចចុះសំបុត្រអាពាហ៍ពិពាហ៍បាន ក្នុងករណីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលមានការជំទាស់ចំពោះការរៀបអាពាហ៍ពិពាហ៍ ក៏ភាគីទាំងពីរមានសិទ្ធិពេញលេញក្នុងការសម្រេចការរៀបអាពាហ៍ពិពាហ៍ គឺផ្ទុយស្រលះពីអនីតិជន។ ចំពោះបញ្ហាចោទ គឺការរៀបអាពាហ៍ពិពាហ៍រវាងអនីតិជន និងនីតិជនទើបមានការលំបាក និងស្មុគស្មាញច្រើន ប្រសិនបើអនីតិជនមានបំណងចង់រៀបអាពាហ៍ពិពាហ៍នោះចាំបាច់ត្រូវមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលជាមុនសិនទើបអាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីអ្នកមានអំណាចមេបា ឬអាណាព្យាបាលរបស់អនីតិជននោះមានម្ខាងយល់ព្រម និងម្ខាងទៀតមិនយល់ព្រមក៏អនីតិជននោះអាចរៀបអាពាហ៍ពិពាហ៍បានដែរ ពោល គឺឲ្យតែមានការយល់ព្រមពីសំណាក់ភាគីម្ខាងអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលនោះជាការស្រេច។ ប៉ុន្តែប្រសិនបើ ក្នុងករណីអ្នកដែលមាន

14 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨។

អំណាចមេបា ឬអ្នកអាណាព្យាបាលរបស់ អនីតិជននោះមិនយល់ព្រមទាំងពីរនោះអនីតិជនអាចដាក់ពាក្យសុំទៅតុលាការបាន។ ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់មាត្រា៩៥៣ ចំណុចទី៣ បានចែងថា "ក្នុងករណីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុ សមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្ដីជំនួសការយល់ព្រមនោះបាន" [15] ។ សរុបសេចក្ដីមក ប្រសិនបើអនីតិជនមានបំណងចង់រៀបអាពាហ៍ ពិពាហ៍ ជំហានដំបូងត្រូវតែមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលជាមុនសិន ប្រសិនបើមានម្ខាងមិនយល់ព្រម ឲ្យតែមានម្ខាងទៀតយល់ព្រមក៏អាចប្រព្រឹត្តទៅបានដែរ។ តែករណីដែលគ្មានការយល់ព្រមទាំងសងខាងដោយគ្មានមូលហេតុត្រឹមត្រូវ អនីតិជនអាចមានជម្រើសចុងក្រោយ គឺស្នើសុំទៅតុលាការដើម្បីសម្រេចសេចក្ដីជំនួសអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលរបស់អនីតិជននោះបាន សេចក្ដីសម្រេចរបស់តុលាការ អាចធ្វើឲ្យអនីតិជនដែលមិនមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលនោះរៀបអាពាហ៍ពិពាហ៍បានស្របទៅតាមច្បាប់ ដោយការសម្រេចរបស់តុលាការ។

### ១.១.៨៖ គោលការណ៍ហាមឃាត់មិនអោយមានការរៀបអាពាហ៍ពិពាហ៍

ដោយយោងតាមការបកស្រាយខាងលើ អាពាហ៍ពិពាហ៍មួយអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីភាគីទាំងសងខាងដែលជានីតិជនជាមុនសិន។ ទោះយ៉ាងណាក្ដីយើងសង្កេតឃើញថាទោះបីជាមានការយល់ព្រមពីភាគី ក៏អាពាហ៍ពិពាហ៍នោះមិនអាចប្រព្រឹត្តទៅបានទេ បើសិនជាអាពាហ៍ពិពាហ៍នោះ ធ្វើខុសនឹងលក្ខខណ្ឌដែលមានចែងក្នុងបញ្ញត្តិច្បាប់មួយចំនួនដូចជា៖

- **ការហាមឃាត់មិនអោយមានទ្វេពន្ធភាព**

ទ្វេពន្ធភាពគឺ សំដៅលើ ភាពនៃបុគ្គលម្នាក់ ដែលពុំទាន់រំលាយចំណងអាពាហ៍ពិពាហ៍មុនផង ហើយរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀត ឬភាពមានប្ដីពីរឬប្រពន្ធពីរ[16]។ ប្រទេសកម្ពុជាបានប្រកាន់យក របបឯកពន្ធភាពដែលនាំអោយមានការហាមឃាត់ដល់ការរៀបអាពាហ៍ពិពាហ៍ដែលមានភាពជាន់គ្នាមានន័យថាបុរស ឬ នារីដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយ មិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានទេ លើកលែងតែបានលែងលះ ឬ សហព័ទ្ធណាម្ខាងទទួលមរណភាព។

15 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៣។

16 សន្ទានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧

ដូចនេះ បុគ្គលដែលមានសហព័ទ្ធហើយពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[17]។ ហេតុនេះស្តែងអោយឃើញថាបើទោះបី ជាអាពាហ៍ពិពាហ៍មួយបានកើតចេញពីការព្រមព្រៀងក្តីតែបើភាគីខាងណាមួយមានចំណងអាពាហ៍ពិពាហ៍មួយដែលមិនទាន់បានកាត់ផ្តាច់នៅឡើយទេនោះ មានន័យថាអាពាហ៍ពិពាហ៍ថ្មីមួយនឹងមិនអាច កើតឡើងបានឡើយ។ មាត្រានេះចែងឡើងក្នុងគោលបំណងដើម្បីកុំអោយមានការប៉ះពាល់ទៅដល់ ភាពថ្លៃថ្នូររបស់សង្គមក៏ដូចជាកត្តាជីវភាពប្រចាំថ្ងៃរបស់សហព័ទ្ធនីមួយៗផងដែរ។

- **ការហាមឃាត់មិនអោយមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត**

បុរស និងនារីដែលជាភាគីនៃអាពាហ៍ពិពាហ៍បានដល់នីតិភាព និងបានបង្ហាញឆន្ទៈថាយល់ព្រមឲ្យមានអាពាហ៍ពិពាហ៍កើតឡើងយ៉ាងណាក្តីក៏អាពាហ៍ពិពាហ៍នោះមិនអាចប្រព្រឹត្តបានដែរ បើភាគីទាំងសងខាងជាញាតិលោហិតខ្សែរផ្ទាល់ ឬ សាខាញាតិលោហិតទាំងបីថ្នាក់រាប់ទាំងថ្នាក់ទីបីផង[18]។ បើផ្អែកតាមសទ្ធានុក្រមផ្នែករដ្ឋប្បវេណីញាតិលោហិត គឺញាតិដែលមានឈាមជ័រជាមួយគ្នាដូចជា ឪពុក និងកូន ឬម្តាយ និងកូន។ ការហាមឃាត់មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតព្រោះដោយហេតុថាវាមានការប៉ះពាល់ទាក់ទងនឹងកត្តាសង្គម ក៏ដូចជាកត្តាជីវសាស្ត្រផងដែរ។ តាមសីលធម៌សង្គម ការរៀបការរវាងញាតិលោហិត គឺវាមានភាពមិនសមរម្យហើយវាខុសនឹងសីលធម៌ និងមិនមានការទទួលស្គាល់ពីសង្គមឡើយ។ លើសពីនេះទៀតនោះ បើផ្អែកតាមផ្នែកជីវសាស្ត្រការ រួមរស់នៅជាមួយសាច់ញាតិឯងហើយបន្តនូវទាយាទ គឺនាំអោយទាយាទនោះមានសុខភាពមិនល្អ ជួនកាលអាចមានការចុះខ្សោយខាងបញ្ញា ស្មារតីថែមទៀតផង ដូចនេះហើយទើបច្បាប់បានធ្វើការ ហាមឃាត់ចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងរវាងញាតិលោហិត។ ថ្វីត្បិតតែទំនាក់ទំនងញាតិត្រូវបានបញ្ចប់តាមរយៈការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និងការកាត់កាល់នៃកូនសុំពេញលេញ ក៏ទំនាក់ទំនងតាមផ្នែកធម្មជាតិមិនត្រូវបានបញ្ចប់ដែរ ហេតុនេះហើយការហាមឃាត់មិនឲ្យមានអាពាហ៍ពិពាហ៍ចំពោះខ្សែរលោហិតនេះនៅតែមានការហាមឃាត់ដដែល។

- **ការហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ**

17 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៩។

18 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥១។

ញាតិពន្ធ គឺជាចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត (សាច់ថ្លៃ)[19]។ អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែរផ្ទាល់ និងសាខាញាតិពន្ធនៅក្នុងបីថ្នាក់រាប់ទាំងថ្នាក់ទីបីផង[20]។ ដូចនេះ បុគ្គលដែលជាញាតិពន្ធខ្សែរផ្ទាល់នឹងគ្នាមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ ទោះបីក្រោយមកបានផ្តាច់ទំនាក់ទំនងញាតិពន្ធជាមួយគ្នាហើយក្តី។ឧទាហរណ៍ លោកថម មានប្រពន្ធម្នាក់ឈ្មោះនារី ហើយនារីមានប្អូនស្រីម្នាក់ឈ្មោះវីណា បន្ទាប់ពីលោកថមនិងនារីបានលែងលះគ្នាចប់សព្វគ្រប់ទៅតាមបញ្ញត្តិច្បាប់ហើយ លោកថមបានស្រលាញ់ប្អូនថ្លៃរបស់ខ្លួន គឺណារីហើយមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង ប៉ុន្តែអាពាហ៍ពិពាហ៍នេះមិនអាចកើតឡើងបានឡើយ បើទោះបីជាទំនាក់ទំនងញាតិត្រូវបានរលត់ក៏ដោយ។

- **ការហាមឃាត់មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍ដែលធ្វើតាមរយៈភ្នាក់ងាររើសគូស្រករ**

បានជាមានការហាមឃាត់ចំពោះការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ព្រោះវាមានភាគរយខ្ពស់ណាស់ដែលនាំឲ្យមានការឆបោក ឬបន្លំក្នុងគោលបំណងបង្កើតនូវចំណងអាពាហ៍ពិពាហ៍ក្លែងក្លាយរវាងពលរដ្ឋខ្មែរ និងជនបរទេសដើម្បីធានាឲ្យសាមីខ្លួនជនជាតិខ្មែរអាចទៅរស់នៅស្រុកកំណើតរបស់សហព័ទ្ធរបស់ខ្លួនដែលជាជនបរទេសបាន បន្ទាប់មកនឹងធ្វើការលែងលះគ្នាព្រោះការរៀបអាពាហ៍ពិពាហ៍នោះ គឺនៅក្នុងគោលបំណងដើម្បីទទួលបានសញ្ជាតិ និងរស់នៅ ឬប្រកបអាជីវកម្មផ្សេងៗតែប៉ុណ្ណោះ។ លើសពីនេះទៅការហាមឃាត់នេះ គឺដើម្បីការពារពលរដ្ឋខ្មែរពីឆបោកផ្សេងៗ ព្រោះកន្លងមកយើងសង្កេតឃើញថាមានស្ត្រីរងគ្រោះជាច្រើនត្រូវបានជនបរទេសបោកបញ្ឆោត និងយកទៅប្រទេសរបស់ខ្លួនហើយបង្ខំឲ្យធ្វើអ្វីដែលមិនស្របទៅនឹងឆន្ទៈរបស់ជនរងគ្រោះ និងពេលខ្លះអាចឈានទៅដល់ការជួញដូរផ្លូវភេទស្ត្រីថែមទៀតផង ។ ហេតុនេះហើយ ទើបច្បាប់បានបញ្ញត្តិ "ហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម"[21]

19 សន្ធានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

20 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥២។

21 អនុក្រឹត្យស្តីពីការរៀបពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣អនក្រ.មក,១២ ខែវិច្ឆិកាឆ្នាំ២០០៨,មាត្រា៣

# ជំពូកទី២

# បែបបទនៃការរៀប
# អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ
# និងជនបរទេស

# ជំពូកទី២

# បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

## ២.១ កំជាប់ពាក្យ ឬពិធីលើកស្លា ឬពិធីភ្ជាប់ពាក្យ

### ២.១.១ ៖ និយមន័យ

កំជាប់ពាក្យ ត្រូវបង្កើតតាមកិច្ចសន្យាដែលបុរស និងនារី បានព្រមព្រៀងគ្នាថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានាពេលអនាគត ដោយសន្យាថាធ្វើពិធីកំជាប់ពាក្យ[22]។ ដោយហេតុថាពិធីនេះ គឺប្រជាជនខ្មែរភាគច្រើននិយមធ្វើមុនពេលរៀបអាពាហ៍ពិពាហ៍ ក្នុងគោលបំណងដើម្បីភ្ជាប់និស្ស័យរវាងអនាគតស្វាមីភរិយាដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត និងចង់បង្ហាញថាបុរស និងនារីសុទ្ធតែមានម្ចាស់ហើយ។ ម៉្យាងទៀត ដោយក្រឡេកឃើញថាពិធីភ្ជាប់ពាក្យនេះ មិនមានលក្ខណៈផ្លូវការឡើយ គឺថាមានន័យថា គូភាគីមានសិទ្ធិមិនរៀបចំពិធីនេះមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បានដែរ។ ផ្ទុយមកវិញ ប្រសិនបើភាគីទាំងសងខាងសម្រេចចិត្តរៀបចំពិធីកំជាប់ពាក្យនេះឡើងហើយត្រូវមានកាតព្វកិច្ចទទួលខុសត្រូវ រាល់ការកែប្រែ ឬរំលាយពិធីកំជាប់ពាក្យនោះ ដោយភាគីម្ខាងទៀតអាចទាមទារ ការសងជំនួនមកវិញ។

### ២.១.២ ៖ លក្ខខណ្ឌនៃការបង្កើត

កំជាប់ពាក្យ គឺកើតឡើងតាមរយៈការសន្យាគ្នារ រវាងភាគីទាំងសងខាងថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។ ពិធីភ្ជាប់ពាក្យនេះប្រៀបដូចជាការប្រកាសថានឹងមានពីធីអាពាហ៍ពិពាហ៍កើតមានឡើងនៅពេលខាងមុខ។ ដោយលក្ខខណ្ឌគឺ ភាគីទាំងពីរត្រូវតែមានភេទផ្ទុយគ្នា ហើយមានឆន្ទៈក្នុងការព្រមព្រៀងរៀបចំពិធីកំជាប់ពាក្យនេះឡើងដោយគ្មានការបង្ខិតបង្ខំពីសំណាក់ភាគីណាម្ខាង ឬពីតតីយជនឡើយ។ បើយោងទៅតាមសម័យបុរាណ ការបង្កើតពិធីកំជាប់ពាក្យនេះ គឺធ្វើតាម លក្ខខណ្ឌមួយចំនួនដូចជា ការចូលថៃថ្ងូរ ការស្ដីដណ្ដឹង (ជា៣ដំណាក់ការ) ។ ប៉ុន្តែបច្ចុប្បន្ន គឺគេកាត់ចោលនៅសល់តែមួយដំណាក់ការនោះទេ ពីព្រោះត្រូវចំណាយថវិការច្រើន និងពេលវេលាយូរដោយ ការចូលថៃថ្ងូរ និងការស្ដីដណ្ដឹង គឺធ្វើឡើងតែម្ដងទេ ឲ្យតែមានការព្រមព្រៀងគ្នាហើយឪពុកម្ដាយទាំងសងខាងយល់ព្រមជាការស្រេច ដោយមានការបំពាក់ជំនួនឲ្យគ្នាទៅវិញទៅមកដូចជា ចិញ្ចៀន ខ្សែក ឬអ្វីផ្សេងទៀតទៅតាមសមត្ថភាពដែលភាគីមាន និងការនិយមទៅតាមបរិបទសង្គម។

22 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៥។

ប្រសិនបើពិធីកំជាប់ពាក្យត្រូវបានរំលាយ ដោយមានបញ្ហាណាមួយ ដូចជាការទទួលមរណៈភាពឬការរៀបអាពាហ៍ពិពាហ៍ ឬការបដិសេធចោលការរៀបអាពាហ៍ពិពាហ៍នាពេលអនាគត ដោយ មានមូលហេតុ ឬគ្មានមូលហេតុក្តី ភាគីម្ខាងទៀតអាចទាមទារឲ្យសងជំនូនមកវិញបាន។

### ២.១.៣៖ ការសងជំនូន

ថ្វីត្បិតតែពិធីបានចប់សព្វគ្រប់ហើយក្តី បើនៅក្នុងករណីដែលមានបញ្ហាណាមួយកើតឡើងនៅ ពេលខាងមុខដែលនាំអោយមានការរាក់ស្ទះដល់ការរៀបអាពាហ៍ពិពាហ៍នោះភាគីម្ខាងទៀតអាចទាមទាអោយមានការសងនូវជំនូនវិញបាន។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា"ក្នុងករណីដែលកំជាប់ពាក្យបាន រលាយភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍អាចទាមទារអោយភាគីម្ខាងនោះសងជំនូននោះមកវិញបាន" [23] ។ ប៉ុន្តែមាត្រានេះអាចអនុវត្តបានចំពោះតែ ក្នុងករណីដែលភាគីខាងណាមួយដែលបដិសេធចោលកំជាប់ពាក្យដោយមិនមានហេតុផលត្រឹមត្រូវតែប៉ុណ្ណោះ។ ព្រោះថាការផ្តាច់ពាក្យដែលមិនសមហេតុវានាំអោយមានការប៉ះពាល់ដល់កិត្តិយសរបស់ ភាគីម្ខាងទៀតហើយវាស្មើនឹងការមិនគោរពនូវកាតព្វកិច្ចរបស់ខ្លួនផងដែរ។ ចំពោះជំនូនវិញ គឺមិនមែន សំដៅតែទៅលើជំនូនដែលភាគីជូនគ្នានោះទេ គឺរាប់បញ្ចូលទាំងប្រាក់ថ្លៃរៀបចំពិធីកំជាប់ពាក្យការជួល រោង និងថ្លៃសោហ៊ុយផ្សេងទៀតក្នុងពេលរៀបចំពិធីកំជាប់ពាក្យ លើសពីនេះទៅទៀត ប្រសិនបើភាគី បានកក់រោងសម្រាប់រៀបចំពិធីមង្គលការ និងបានរៀបចំជូលចុងភៅ និងសំភារៈដើម្បីត្រៀមរៀបចំពិធី មង្គលការក៏អាចរាប់ជាជំនូនដើម្បីទាមទារមកវិញបានដូចគ្នា ដោយមិនសំដៅទៅលើតែជំនូនក្នុងការ រៀបចំពិធីកំជាប់ពាក្យតែមួយមុខនោះទេ ផ្ទុយមកវិញប្រសិនបើពិធីកំជាប់ពាក្យមិនទាន់បានប្រព្រឹត្តនៅ ឡើយដោយមានការសន្យាថានឹងរៀបពិធីកំជាប់ពាក្យនោះភាគីដែលត្រូវបានគេបដិសេធមិនរៀបពិធី កំជាប់ពាក្យមិនអាចទាមទារជំនូនបាននោះទេ ពីព្រោះភាគីទាំងពីរមិនទាន់បានជាប់កាតព្វកិច្ចរវាងគ្នានោះឡើយ។

### ២.១.៤៖ អាជ្ញាយុកាលនៃការដាក់ពាក្យបណ្តឹង

នៅពេលដែលពិធីកំជាប់ពាក្យត្រូវបានរំលាយ ឬមានការបដិសេធចោលដោយគ្មានមូលហេតុ ត្រឹមត្រូវ ភាគីម្ខាងអាចធ្វើការប្តឹងទៅតុលាការ ដើម្បីទាមទារសំណងមកវិញដោយរាប់បញ្ចូលទាំង ជំនូន និងសំណងនៃការខូចខាតផ្សេងៗទៀតតាមការជាក់ស្តែង។ ចំពោះការដាក់ពាក្យបណ្តឹងដើម្បីទាមទារនូវការសងជំនូនមកវិញគឺភាគីខាងដើមបណ្តឹង "ត្រូវប្តឹងនៅក្នុងអំឡុងពេល១

23 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៥។

(មួយ)ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះត្រូវបានរលាយ"[24]។ ប្រសិនបើ ហួសអាជ្ញាយុកាលនៃការដាក់ពាក្យបណ្តឹងនោះភាគីដែលរងគ្រោះដោយការរំលាយកំជាប់ពាក្យមិនអាចទាមទារជំនួនមកវិញបានទេ។

## ២.២ ៖ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

### ២.២.១ ៖ ការបំពេញបែបបទ

ការរៀបអាពាហ៍ពិពាហ៍ឲ្យសមស្របតាមផ្លូវច្បាប់មិនមែនត្រឹមតែគោរពទៅតាមលក្ខខណ្ឌគ្រឹះតែប៉ុណ្ណោះទេ តែទាមទារឲ្យមានការគោរពនូវលក្ខខណ្ឌទម្រង់ផងដែរ។ លក្ខខណ្ឌទម្រង់ គឺទាក់ទងនឹងនីតិវិធីនៃការដាក់ពាក្យសុំរៀបអាពាហ៍ពាហ៍ ការជូនដំណឹងជាសារធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅមន្ត្រីអត្រានុកូលដ្ឋានជាដើម។ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺវាស្រដៀងគ្នានឹងការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ គ្រាន់តែមានភាពខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ។ ជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌ ហើយត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធី។ លក្ខខណ្ឌចំពោះជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ គឺចាំបាច់ត្រូវតែមានអាយុក្រោម ៥០ឆ្នាំ និងមានប្រាក់ចំណូលយ៉ាងតិច ២៥០០$(ពីរពាន់ប្រាំរយដុល្លាអាមេរិក) ប៉ុន្តែក្រោយមកមានការស្នើទៅនាយករដ្ឋមន្ត្រីតាមសំណើររបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិលេខ ៧៨៧៣ កបទ-សអ/ច្បក២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ បានស្នើឲ្យមានការដកចេញនូវលក្ខខណ្ឌអាយុ ដោយមិនចាំបាច់មានអាយុក្រោម៥០ឆ្នាំទៀតទេ គឺអោយតែមានប្រាក់ចំណូលយ៉ាងតិច ២៥០០$(ពីរពាន់ប្រាំរយដុល្លាអាមេរិក) អាចរៀបអាពាហ៍ពិពាហ៍ជាមួយពលខ្មែរបានហើយ[25] បន្ទាប់ពីគោរពតាមលក្ខខណ្ឌប្រាក់ចំណូល ហើយនោះឈានចូលទៅដល់នីតិវិធីក្នុងការស្នើសុំរៀបអាពាហ៍ពិពាហ៍វិញម្តង។ យោងតាមអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានកំណត់ថា អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈបាន លុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានដែលសាមីខ្លួនទាំងពីរ

24 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៧។

25 ប្រកាសលេខ៧៨៧៣ កបទ-សអ/ច្បក២, ២៦ តុលា ២០១៨, របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

បានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។ ដូចនេះ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយត្រឹមត្រូវតាមច្បាប់ គឺភាគីទាំងសងខាងត្រូវគោរពនូវលក្ខខណ្ឌ និងគោរពតាមដំណាក់កាលមួយចំនួនដូចខាងក្រោម៖

### ២.២.២៖ នីតិវិធីនៅក្រសួងការបរទេស

សាមីខ្លួនជាជនបរទេស ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងពលរដ្ឋខ្មែរត្រូវតែបំពេញបែបបទនឹងដាក់ពាក្យសុំទៅ "ក្រសួងការបរទេស និងសហប្រតិបត្តិការនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងផ្តល់យោបល់លើសុំណុំឯកសាររបស់ជនបរទេសក្រសួងការបរទេស និងសហប្រតិបត្តិការ នៃព្រះរាជាណាចក្រកម្ពុជាត្រូវជូនដំណឹងទៅកាន់សាមីខ្លួនជាជនបរទេសវិញក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃធ្វើការ"[26]។ បន្ទាប់ពីបានត្រួតពិនិត្យចប់សព្វគ្រប់រាល់សុំណុំឯកសារទាំងនោះថាត្រឹមត្រូវ និងមិនមានភាពមិនប្រក្រតីណាមួយនោះទេ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តជាតិត្រូវបញ្ជូនទៅក្រសូងមហាផ្ទៃ ដើម្បីធ្វើការពិនិត្យបន្ថែមទៀត និងជូនពត៌មានទៅកាន់ស្ថាប័នដែលពាក់ព័ន្ធ។ ឯកសារពាក់ព័ន្ធដែលចាំបាច់ក្នុងការបំពេញបែបបទនៅឯក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជារួមមាន៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃលិខិតឆ្លងដែន នៃសាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជាដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ពីភាពនៅលីវ ឬពោះម៉ាយ ឬម៉េម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជាជនបរទេសដែលធានាដល់ជីវភាពរស់នៅដែលចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស[27]។

---

26 អនុក្រឹត្យស្តីពីការរៀបពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣អនក្រ.មក,១២ ខែវិច្ឆិកាឆ្នាំ ២០០៨,មាត្រា៧

27 អនុក្រឹត្យស្តីពីការរៀបពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣អនក្រ.មក,១២ ខែវិច្ឆិកាឆ្នាំ ២០០៨,មាត្រា៦

បញ្ជាក់៖ ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា។

### ២.២.៣ ៖ នីតិវិធីនៅក្នុងក្រសួងមហាផ្ទៃ

បន្ទាប់ពីទទួលបាននូវសុំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដែលបានបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការនៃព្រះរាជាណាចក្រកម្ពុជាមក ដោយផ្អែកតាមអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ក្រសួងមហាផ្ទៃ មានតួនាទីក្នុងការ "ចុះបញ្ជីសុំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនជាជនបរទេសវិញក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ។ បន្ទាប់ពីជូនដំណឹងទៅឲ្យសាមីខ្លួនជនបរទេសរួចរាល់ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ" [28] ផងដែរ។ ក្រសួងមហាផ្ទៃក៏មានភារកិច្ចក្នុងការពិនិត្យនីត្យានុកូលភាពលើសុំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជាពលរដ្ឋខ្មែរ។

### ២.២.៤ ៖ នីតិវិធីនៅមន្ត្រីអត្រានុកូលដ្ឋានកម្ពុជា

នៅពេលមានការត្រួតពិនិត្យ ការផ្តល់យោបល់ និងបានចុះបញ្ជីទៅលើសុំណុំឯកសារទាក់ទងនឹងពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះមក សាមីខ្លួនជនបរទេសមានតួនាទីក្នុងការដាក់ពាក្យសុំទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

ចំពោះពលរដ្ឋខ្មែរដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនឹងជនបរទេស ក៏ត្រូវរៀបចំសុំណុំឯកសារមួយចំនួនក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនកំពុងរស់នៅផងដែរ។ "សាមីខ្លួនពលរដ្ឋខ្មែរត្រូវភ្ជាប់មកជាមួយនឹងសុំណុំឯកសារដែលពាក់ព័ន្ធមួយចំនួនដូចជា៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ

28 អនុក្រឹត្យស្តីពីការរៀបពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣អនក្រ.មក,១២ ខែវិច្ឆិកាឆ្នាំ ២០០៨,មាត្រា៨

- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា”[29]។

គួរបញ្ជាក់ផងដែរថា ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសុំណុំឯកសាររបស់សាមីខ្លួនជាពលរដ្ឋខ្មែរត្រូវតែដាក់ស្របគ្នាជាមួយនឹងពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជនជាពលរដ្ឋខ្មែរ។ “មន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់មានភារកិច្ចពិនិត្យ និងសម្រេចលើពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនបុរស និងនារីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃនៃថ្ងៃការងារ បន្ទាប់ពីទទួលបានពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសុំណុំឯកសារភ្ជាប់ ហើយបានត្រួតពិនិត្យទៅលើសុំណុំឯកសារចប់សព្វគ្រប់រួចរាល់អស់ហើយមន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដោយមានវត្តមានរបស់សាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ក្រោយពេលដែលមន្ត្រីអត្រានុកូល ដ្ឋានចេញនូវប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រួចរាល់ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ទាំងនេះ ត្រូវយកទៅបិទផ្សាយនៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជាជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងនៅលំនៅដ្ឋានអចិន្ត្រៃយ៍ នៅសាលាឃុំ សង្កាត់នៃសាមីខ្លួនពលរដ្ឋខ្មែរក្នុងរយៈពេល១០ថ្ងៃ ដើម្បីឲ្យស្របទៅនឹងការកំណត់ក្នុងបែបបទ និងនីតិវិធីការងារអត្រានុកូលដ្ឋាន។ បន្ទាប់ពីធ្វើការបិទផ្សាយអស់រយៈពេល១០ថ្ងៃកន្លងមក បើគ្មានការប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះទេ សាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍”[30]។

## ២.៣ ៖ ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ថ្វីត្បិតតែអាពាហ៍ពិពាហ៍អាចធ្វើបានរវាងនីតិជន និងនីតិជន ដែលមានសមត្ថភាពពេញក្នុងការបញ្ចេញឆន្ទៈក្តី តែក៏មានលក្ខខណ្ឌមួយចំនួនដែលអាចឲ្យជនដែលត្រូវបានគេកំរិតសមត្ថភាពអាចរៀបអាពាហ៍ពិពាហ៍បានដែរ តួយ៉ាងដូចជាការរៀបអាពាហ៍ពិពាហ៍ដែលធ្វើឡើងរវាង អនីតិជនចាប់ពី១៦ឆ្នាំឡើងទៅ និង ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ។

---

29 អនុក្រឹត្យស្តីពីការរៀបពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣អនក្រ.មក,១២ ខែវិច្ឆិកាឆ្នាំ ២០០៨,មាត្រា៩

30 អនុក្រឹត្យស្តីពីការរៀបពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣អនក្រ.មក,១២ ខែវិច្ឆិកាឆ្នាំ ២០០៨,មាត្រា១០

### ២.៣.១ ៖ ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនចាប់ពី១៦ ឆ្នាំ

"ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជននោះ"[31]។ ការតម្រូវឲ្យមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលបែបនេះ គឺដើម្បីចង់បង្គ្រប់ភាពខ្វះខាតខាងផ្នែកបញ្ញា និងភាពវិនិច្ឆ័យរបស់អនីតិជននោះ ដូចនេះមានន័យថា ការរៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជនអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលជាមុនសិន ប៉ុន្តែក្នុងករណី "បើអ្នកដែលអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលតែម្ខាងជាការគ្រប់គ្រាន់"[32]។

បើទោះជាច្បាប់បានចែងបែបនេះក្តី តែច្បាប់ការពារផលប្រយោជន៍ដល់អនីតិជនក្នុងករណីដែលអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលបានប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយបំពានទៅលើអនីតិជននោះដូចជាការបដិសេធមិនឲ្យមានការរៀបអាពាហ៍ពិពាហ៍ដោយមិនមានហេតុផលត្រឹមត្រូវ។ ដូចនេះ "ក្នុងករណីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់នីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុដែលសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន"[33]។ ហេតុនេះ បញ្ជាក់ឲ្យឃើញថា ស្មារតីរបស់ក្រមរដ្ឋប្បវេណី បានបើកសិទ្ធិសេរីភាពដល់អនីតិជនក្នុងការស្វែងរកដៃគូជីវិតឲ្យតែមានការគោរពតាម លក្ខខណ្ឌខាងលើជាការស្រេច។

### ២.៣.២ ៖ ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជនដែលនៅក្រោមអាណាព្យាបាលទូទៅ "គឺសំដៅលើជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលទៅតាមច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី"[34]។ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅអាចរៀបអាពាហ៍ពិពាហ៍បានដែរតែប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅនោះមាន សមត្ថភាពគ្រប់គ្រាន់នៅក្នុងការបង្ហាញឆន្ទៈបានដែលកំរិតមួយដែលអាចទទួលយកបាន។ ក្រមរដ្ឋប្បវេណីក៏បានកំណត់អំពីលក្ខខណ្ឌនេះផងដែរ "ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមា ដែលចាំបាច់

31 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៣ កថាខណ្ឌ១។
32 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៣ កថាខណ្ឌ២។
33 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨ កថាខណ្ឌ៣។
34 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៤ កថាខណ្ឌ១។

ដើម្បីរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកមានអាណាព្យាបាលទូទៅឡើយ។"[35]

### ២.៣.៣ ៖ ការរៀបអាពាហ៍ពិពាហ៍របស់ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ

ជនដែលនៅក្រោមហិតូបត្ថម្ភ គឺ "ជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី"។ ថ្វីត្បិតតែក្រមរដ្ឋប្បវេណីមិនបានកំណត់អំពីការរៀបអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភយ៉ាងណាក្តី តែទោះយ៉ាងណាក៏ដោយមិនមែនមានន័យថាជននៅក្រោមហិតូបត្ថម្ភនោះមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ បើក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភនោះមានសមត្ថភាពគ្រប់គ្រាន់ នៅក្នុងការបង្ហាញឆន្ទៈ និងមានការដឹងខុសត្រូវអំពីដែលខ្លួនបានធ្វើ នោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភអាចរៀបអាពាហ៍ពិពាហ៍បានដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។

## ២.៤ ៖ ការចាត់ទុកប្តីប្រពន្ធដែលគ្មានអនុភាពតាមផ្លូវច្បាប់

### ២.៤.១ ៖ ការរស់នៅជាមួយគ្នាជាអនីតិសង្វាសជន

ការរស់នៅជាអនីតិសង្វាសជន គឺការរស់នៅរវាងបុរស និងនារីជាលក្ខណៈប្តីប្រពន្ធតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ និងរៀបការតាមប្រពៃណី។ ការរស់នៅបែបនេះគឺ មិនសូវមានភាពពេញនិយមឡើយនៅកម្ពុជា ព្រោះប្រជាជនកម្ពុជាជឿជាក់ថាការរស់នៅដោយបែបនេះ គឺវាមានភាពផ្ទុយពីប្រពៃណីខ្មែរ និងខុសសីលធម៌សង្គម។ ផ្ទុយទៅវិញការរស់នៅបែបនេះគឺជាការពេញនិយមនៅក្នុងបណ្តាប្រទេសនានានៅខាងបែកអឺរ៉ុប។ បានជាការរស់នៅជាមួយគ្នាដោយមិនមានការចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះ ព្រោះពួកគេមិនចង់មានចំណាង និងចង់ស្វែងយល់ចិត្តគ្នាឲ្យកាន់តែច្បាស់បង្ការការមានទំនាស់នៅថ្ងៃក្រោយ និងពិបាកក្នុងការលែងលះ។ ប្តីប្រពន្ធដែលរស់នៅជាមួយគ្នាបែបនេះត្រូវបានចាត់ទុកថាគ្មានអនុភាពតាមផ្លូវច្បាប់។

### ២.៤.២ ៖ ការរស់នៅជាមួយគ្នាតាមប្រពៃណីតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍

ប្រជាជនកម្ពុជាមួយចំនួននៅតែខ្វះការយល់ដឹងអំពីបញ្ហាទាំងនេះ ថាតើវានឹងនាំនូវផលវិបាកបែបណាខ្លះនៅពេលដែលអាពាហ៍ពិពាហ៍មួយធ្វើឡើងដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍។ ដោយគិតថាអាពាហ៍ពិពាហ៍មួយ គឺគ្រាន់តែប្រព្រឹត្តទៅតាមទំនៀមទំលាប់ប្រពៃណី

35 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៩។

ទៅបានហើយព្រោះគ្រាន់តែឲ្យសាច់ញាតិបងប្អូនដឹងលឺទៅ គឺគ្រប់គ្រាន់ហើយ តែផ្ទុយមកវិញ អាពាហ៍ពិពាហ៍នោះមិនមែនជាអាពាហ៍ដែលស្របទៅតាមច្បាប់នឹងអាចឲ្យគេទទួលស្គាល់បាន ឡើយ ឬបើមានវិវាទណាមួយកើតឡើងក៏មិនអាចឲ្យច្បាប់ការពារដែរ។

## ២.៥ ៖ ការបង់កម្រៃសេវារដ្ឋបាល

ជាទូទៅ យើងដឹងស្រាប់ហើយថារដ្ឋតែងតែជួយសម្របសម្រួលដល់ប្រជាពលរដ្ឋដោយមិន ត្រូវការកម្រៃតបស្នង ប៉ុន្តែដើម្បីធានាដល់សេវាផ្នែករដ្ឋបាល គឺតែងតែមានការបង់កម្រៃសេវារដ្ឋបា ល ដើម្បីធ្វើការធានាឲ្យសេវានោះ មានភាពល្អប្រសើរ និងមានភាពឆាប់រហ័ស យ៉ាងណាមិញ ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសក៏មានការកំណត់នូវសេវា ដើម្បីបង់ ចូលស្ថាប័នដែលពាក់ព័ន្ធ។

### ២.៥.១ ៖ នៅក្រសួងការបរទេស

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ចំពោះនីតិវិធីក្នុងការបង់ប្រាក់កម្រៃ ចូលផ្នែករដ្ឋបាល គឺអាស្រ័យទៅលើប្រកាសរបស់ក្រសួងការបរទេស ស្តីពីការផ្តល់សេវាសាធារ ណៈ របស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តការអន្តរជាតិដែលបានកំណត់តម្លៃសេវាដោយ តារាង ឧបសម្ព័ន្ធខាងក្រោយមានចំនួន ១០០០០៛ (មួយម៉ឺនរៀល) សម្រាប់បង់ចូលក្រសួងការបរទេ ស។ ចំពោះថេរវេលាក្នុងនីតិវិធីសម្រាប់ការផ្តល់សេវា គឺមានចំនួន ៥ថ្ងៃ គិតតែថ្ងៃធ្វើការប៉ុណ្ណោះ ទេ។

### ២.៥.២ ៖ នៅក្រសួងមហាផ្ទៃ

ការបង់ប្រាក់កម្រៃចូលក្រសួងមហាផ្ទៃ ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស គឺមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ៣៦៦ ប្រក ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។ ការកំណត់ចំពោះតម្លៃសេវាដែលត្រូវបង់ ចូលក្រសួងការបរទេស គឺមានចំនួន ៨៥០០០០ (ប៉ែតសិបប្រាំម៉ឺនរៀល)។ ដោយឡែក ការចែងអំពី តម្លៃ សេវារដ្ឋបាលបែបនេះ ត្រូវបានប្រកាសអន្តរក្រសួងលេខ១៨៤១៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៦ និរាករណ៍នូវកម្រៃសេវារដ្ឋបាលចាស់ចោល ដោយមិនតម្រូវឲ្យមានការបង់ប្រាក់កម្រៃសេវា ចូលផ្នែក រដ្ឋបាលនោះទេ។ ចំពោះថេរវេលាក្នុងនីតិវិធីសម្រាប់ការផ្តល់សេវា គឺមានចំនួន ២៣ថ្ងៃ គិតតែថ្ងៃធ្វើការនោះទេ។

### ២.៥.៣ ៖ នៅរដ្ឋបាល ឃុំ សង្កាត់

នីតិវិធីក្នុងការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសសម្រាប់បង់កម្រៃចូល ផ្នែករដ្ឋបាល ឃុំ សង្កាត់ គឺដូចគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ។ ចំពោះកម្រៃសម្រាប់ស្នើសុំក្នុងការរៀបអាពាហ៍ពិពាហ៍នៅឃុំ សង្កាត់ គឺមិនមានការយកកម្រៃសេវា នោះទេ ប៉ុន្តែប្រសិនបើលើសំបុត្រអាពាហ៍ពិពាហ៍វិញ កម្រៃសេវាត្រូវបែងចែកជា ២ ប្រភេទ គឺការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរចំពោះកម្រៃសេវាមានតម្លៃ ៥០០០ រ (ប្រាំពាន់រៀល) រយៈពេលផ្តល់សេវាក្នុងការធ្វើការគឺ ៣ថ្ងៃ គិតតែថ្ងៃធ្វើការ។ ចំនែកឯសំបុត្រអាពាហ៍ពិពាហ៍រវាង ពលរដ្ឋខ្មែរ និងជនបរទេសវិញ គឺមានតម្លៃ ១៥០០០រ(មួយម៉ឺនប្រាំពាន់រៀល) រយៈពេលផ្តល់សេវាក្នុងការធ្វើការគឺ ៣ថ្ងៃ គិតតែថ្ងៃធ្វើការដូចគ្នា។

## ២.៦ ៖ ទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

### ២.៦.១ ៖ មោឃភាព

មោឃភាពអាពាហ៍ពិពាហ៍ គឺជាឧបសគ្គដែលរាំងស្ទះក្នុងការបង្កើតអាពាហ៍ពិពាហ៍ ដោយមូលហេតុគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រលំលើ មនុស្ស ការបង្ខំ និងមូលហេតុផ្សេងទៀត[36]។ បើសិនជាភាគីណាម្ខាងមិនមានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ ឬ មួយឆន្ទៈនោះកើតចេញពីការបង្ខិតបង្ខំ ពីសំណាក់មេបា អាណាព្យាបាល ឬតតិយជនណាមួយ នោះនាំឲ្យអាពាហ៍ពិពាហ៍នោះរងនូវការមោឃភាព ព្រោះវាជាអាពាហ៍ពិពាហ៍ដែលកើតឡើងផ្ទុយពីឆន្ទៈរបស់បុគ្គល។ លើសពីនេះទៅទៀតអាពាហ៍ពិពាហ៍ក៏រងនូវការមោឃភាពផងដែរ បើសិនជាមានការភាន់ច្រលំទៅលើមនុស្ស។ ឧទាហរណ៍ លោករ៉ូបឺន មានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយលីតា ដោយហេតុថាលីតាមានប្អូនស្រីភ្លោះម្នាក់ឈ្មោះលីដា នាំឲ្យលោករ៉ូបឺន មានការយល់ច្រលំថាលីដាគឺជាលីតា។ដោយមានការភាន់ច្រលំលើមនុស្សបែបនេះទើបនាំឲ្យមានការមោឃភាព។ លើសពីនេះទៅទៀតអាពាហ៍ពិពាហ៍ដែលនាំឲ្យមានការមោឃភាពទៀតនោះ ប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសារធាណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះអាពាហ៍ពិពាហ៍[37]។

---

36 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨។

37 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨ កថាខណ្ឌ២។

### ២.៦.២ ៖ ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការប្រកាសទណ្ឌកម្មដែលលុបចោលបំបាត់អនុភាពនៃអាពាហ៍ពិពាហ៍ឆ្ពោះទៅពេលអនាគតតាមផ្លូវតុលាការដោយសារតែច្បាប់ហាមឃាត់អាពាហ៍ពិពាហ៍របស់ពួកគេទោះបីជាពួកគេជានីតិជន និងមានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ដូចគ្នាក្តី។ អាពាហ៍ពិពាហ៍ដែលត្រូវលុបចោលនោះ គឺជាអាពាហ៍ពិពាហ៍ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ និងគោរពទៅតាមនីតិវិធីរួចរាល់ហើយតែ អាពាហ៍ពិពាហ៍នោះធ្វើឡើងដោយខុសនឹងបញ្ញត្តិច្បាប់ដែលនាំឲ្យមានការប៉ះពាល់ផលប្រយោជន៍ជាសាធារណៈ និងផលប្រយោជន៍ឯកជន។ អាពាហ៍ពិពាហ៍ដែលនាំឲ្យមានការលុបចោលរួមមាន អាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយ ជនមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍រវាងញាតិលោហិត អាពាហ៍ពិពាហ៍រវាងញាតិពន្ធ អាពាហ៍ពិពាហ៍ទ្វេពន្ធភាព និងអាពាហ៍ពិពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់។ លើសពីនេះ បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬគំរាម អាចទាមទារទៅតុលាការ ឲ្យលុបចោល អាពាហ៍ពិពាហ៍នេះបាន ក៏ប៉ុន្តែប្រសិនបើរកឃើញថាការឆបោកនោះមានអំឡុង បីខែកន្លងផុតទៅក្នុងរយៈពេល៣ខែហើយ នោះនាំឲ្យភាគីមិនអាចធ្វើការប្តឹងទៅតុលា សុំឲ្យធ្វើការលុបចោលនោះឡើយ[38]។

## ២.៧ ៖ អនុភាពនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

### ២.៧.១ ៖ ចំពោះទំនាក់ទំនងបុគ្គល

ដោយហេតុថា អាពាហ៍ពិពាហ៍ គឺជាសញ្ញាណគតិយុត្តដែលទាក់ទងនឹងការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលជាច្រើន នោះអានុភាពនៃអាពាហ៍ពិពាហ៍ និងផ្តោតទៅលើទំនាក់ទំនាក់ទំនងញាតិដូចខាងក្រោម៖

#### ២.៧.១.១ ៖ ការបង្កើតទំនាក់ទំនងញាតិពន្ធ

ញាតិពន្ធ គឺសំដៅទៅលើ ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត (សាច់ថ្លៃ)។ ដោយក្រមរដ្ឋប្បវេណី គឺមិនបានចែងឲ្យច្បាស់លាស់អំពីការបង្កើតទំនាក់ទំនងញាតិពន្ធតាមរយៈអាពាហ៍ពិពាហ៍នោះទេ តែផ្ទុយទៅវិញក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ត្រង់មាត្រា៩៤១ បានចែងការរលត់ទំនាក់ទំនងញាតិពន្ធតាមរយៈការលែងលះ ឬមរណភាពរបស់សហព័ទ្ធ។ តាមន័យនេះយើងអាចសន្និដ្ឋានបានថា អានុភាពនៃអាពាហ៍ពិពាហ៍បង្កើតឲ្យមានទំនាក់

38 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៣។

ទំនងញាតិថ្មី ពោលគឺ ញាតិពន្ធ។ លើសពីនេះ ក្រមរដ្ឋប្បវេណីបានកំណត់នូវទំហំញាតិត្រឹមញាតិពន្ធថ្នាក់ទី៣។ ដូចនេះក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍។ ទំនាក់ទំនងរវាងសហព័ទ្ធទៅនឹងញាតិពន្ធត្រូវបានចាប់ផ្តើមដោយស្វ័យប្រវត្តិ។

### ២.៧.១.២ ៖ ការបង្កើតសុំកូនពេញលេញ

ការសុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងញាតិលោហិតតាមផ្លូវច្បាប់ រវាងបុគ្គលដែលជាឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំ។ ទំនាក់ទំនងនេះក៏មានគោលបំណងបង្កើតឲ្យមាននូវសិទ្ធិទទួលបន្តមត៌កតាមរយៈសន្តតិកម្មគឺមានន័យថា "កូនរបស់មតកជន ទោះបីជា កូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកស្មើៗគ្នា"[39]។ ដូច្នេះសិទ្ធិ និងកាតព្វកិច្ចរវាងកូនសុំ និងកូនបង្កើត គឺមានភាពដូចគ្នា។ ការសុំកូនអាចធ្វើទៅបានលុះត្រាណាតែ "បុគ្គលដែលក្លាយជាឪពុក ឬម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ"[40]។ បានជាក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិបែបនេះព្រោះ ដោយហេតុថា របបនៃការសុំកូនពេញលេញ គឺប្រៀបបានដូចជាការបង្កើតគ្រួសារថ្មី និងផ្តល់នូវភាពកក់ក្តៅទៅដល់កូនសុំផងដែរ។ ឪពុក ម្តាយចិញ្ចឹមអាចធ្វើការសុំកូនបាន គឺទាល់តែសហព័ទ្ធទាំងសងខាងបានបង្ហាញឆន្ទៈដូចគ្នា ព្រោះថាបើមានភាគីម្ខាងមិនយល់ស្របនោះទេ ធ្វើឲ្យការគ្រប់គ្រងទៅលើកូនសុំមិនមានភាពល្អប្រសើរ និងពេញលក្ខណៈ នាំឲ្យការសុំកូនមិនអាចកើតឡើងបានឡើយ។

### ២.៧.១.៣ ៖ ការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ប្តី និងប្រពន្ធបានក្លាយទៅជាសហព័ទ្ធពេញសិទ្ធិ "ប្តី ប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុន ពេលរៀបអាពាហ៍ពិពាហ៍បាន"[41]។ ជាទូទៅគេច្រើនប្រើប្រាស់នាមត្រកូលរបស់ប្តីច្រើនជាងប្រពន្ធ។ នៅក្នុងសង្គមខ្មែរការប្តូរនាមត្រកូល ឬ ការប្រើប្រាស់នាមត្រកូលរបស់ប្តី ឬ ប្រពន្ធ គឺមិនសូវមានភាពពេញនិយម ដោយភាគច្រើន គឺច្រើនប្រើប្រាស់នាមត្រកូលរបស់ខ្លួនដដែល ព្រោះមិនចង់ឲ្យមានការស្មុគស្មាញច្រើន។ ដោយឡែក និតីវិធីនៃការផ្លាស់ប្តូរនាម ត្រកូល នៅក្នុងប្រទេសកម្ពុជាត្រូវបានច្បាប់កំណត់យ៉ាងតឹងរឹងដែលតម្រូវអោយមានសេចក្តីសម្រេចពីតុលាការទៀតផង។ ផ្ទុយទៅវិញ នៅក្នុងបណ្តាប្រទេសនានា ការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ គឺមានភាពពេញនិយម

39 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៦ កថាខណ្ឌ២។

40 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០០៨ កថាខណ្ឌ១។

41 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៥។

តួយ៉ាងដូចនៅប្រទេសសហរដ្ឋអាមេរិកការប្តូរនាមត្រកូលមកប្រើប្រាស់នាមត្រកូលរបស់ភាគី គឺវាមានភាពទូទៅ។

### ២.៧.១.៤ ៖ ការទទួលបាននីតិភាព

នីតិភាព សំដៅលើភាពដែលមានអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។ ក្រមរដ្ឋប្បវេណីបានកំណត់អាយុ ១៨ឆ្នាំ បានដល់នីតិភាព ប៉ុន្តែយើងសង្កេតថានៅមានលក្ខខណ្ឌពិសេសមួយចំនួនទៀតដែលអាចឲ្យអនីតិជនទទួលបាននីតិភាព។ តួយ៉ាង "ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍អនីតិជននោះត្រូវចាត់ទុកថាដល់នីតិភាពដោយការរៀបអាពាហ៍ពិពាហ៍នោះ"[42]។ លើសពីនេះទៅទៀតអនីតិជន ដែលបានរៀបអាពាហ៍ពិពាហ៍ហើយត្រូវបានទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការ។ មានន័យថា អាពាហ៍ពិពាហ៍នាំឲ្យបុគ្គលដល់នីតិភាពដោយស្វ័យប្រវត្ត ហើយប្រសិនបើមានការលះលែងកើតឡើង ក៏នីតិភាពនេះមិនរលត់ទៅតាមការលះលែងវិញដែរ។

### ២.៧.១.៥ ៖ ការទទួលបានឋានៈជាអ្នកមានអំណាចមេបា

ចំពោះការរៀបអាពាហ៍ពិពាហ៍ គឺធ្វើឲ្យសហព័ទ្ធទាំងពីរមានសិទ្ធិ ឬ ឋានៈក្លាយទៅអ្នកដែលមានអំណាចមេបាទៅលើកូនស្មុំ ឬកូនចុងទោះបីជាកូននោះជាកូនស្មុំ ឬកូនចុងដែលមានមុនពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏អានុភាពក្រោយការរៀបអាពាហ៍ពិពាហ៍នឹងក្លាយជាអ្នកដែលមានអំណាចមេបា ត្រឹមត្រូវទៅតាមច្បាប់កំណត់។

## ២.៧.២ ៖ ចំពោះកាតព្វកិច្ចកំណត់ដោយក្រមរដ្ឋប្បវេណី

ដោយផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សហព័ទ្ធមានកាតព្វកិច្ចរួមរស់ជាមួយគ្នាជាច្រើនដែលមានមិនមែន ជាកាតព្វផ្តាច់មុខរបស់ប្តី ឬប្រពន្ធតែមួយមុខនោះទេ ដូច្នេះត្រូវឲ្យសហព័ទ្ធ រួមរស់ និងសហការគ្នាទៅវិញទៅមក។

### ២.៧.២.១ ៖ ករណីយកិច្ចរួមរស់ សហការ និងសង្គ្រោះគ្នា

មាត្រា៩៦៦ ក្នុងក្រមរដ្ឋប្បវេណីសំដៅថា "ប្តីប្រពន្ធត្រូវរួមរស់ជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក"[43]។ ប្តី ឬប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការសហការគ្នា និងគោរពគ្នាទៅវិញទៅមកដើម្បីបានជាប្រយោជន៍ដល់គ្រួសារទាំងមូល។ ការរួមរស់ និងសហការគ្នាបែបនេះជាមូល

42 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៨។

43 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៦។

ដ្ឋានគ្រឹះយ៉ាងសំខាន់នៅក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែប្រសិនបើភាគីម្ខាងបានបំពាននូវករណីកិច្ចនេះ នោះភាគីម្ខាងទៀតអាចដាក់ពាក្យបណ្តឹង ទាមទារសំណងការខូចខាតបាន លើសពីនេះទៀត ការបំពាននេះនឹងបង្កជាមូលហេតុនៃការលែងលះ។

### ២.៧.២.២ ៖ សេរីភាពក្នុងការចូលរួមសកម្មភាពសង្គម និងជ្រើសរើសវិជ្ជាជីវៈ

"ប្តី ប្រពន្ធមានសេរីភាពក្នុងការ ជ្រើសរើសវិជ្ជាជីៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន"[44]។ ត្រង់ចំណុចនេះច្បាប់ហាក់បីដូចបើកទូលាយដល់សហព័ទ្ធឲ្យមានការចូលរួមក្នុងសង្គម និងជ្រើសរើសវិជ្ជាជីវៈក្រោយការរៀបអាពាហ៍ពិពាហ៍ គឺសហព័ទ្ធ មានសិទ្ធសេរីភាព ពេញលេញក្នុងការជ្រើសរើស និងសម្រេចចិត្ត។

### ២.៧.២.៣ ៖ ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

យោងតាមមាត្រា ៩៧១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងថា "ប្តី ប្រពន្ធត្រូវមានចំណែកសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើ ទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងទៀត"[45] ។ បញ្ញតិនេះ ទាក់ទងទៅនឹងបន្ទុករួមក្នុងការចំណាយនៅក្នុងគ្រួសារ ដែរតម្រូវឲ្យប្តីប្រពន្ធចែករំលែកសោហ៊ុយ ទៅតាមប្រាក់ចំណូល មិនត្រឹមតែទៅលើការស្នាក់នៅ ការហូបចុក តែប៉ុណ្ណោះទេ តែរួមបញ្ចូលទាំងការចំណាយចំពោះកូន ថ្លៃសិក្សា និងការព្យាបាលផងដែរ។

### ២.៧.២.៤ ៖ ការទទួលខុសត្រូវដោយសាមគ្គីភាព

ប្តីប្រពន្ធក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ គឺត្រូវតែមានបន្ទុករួមមួយ ដើម្បីសាមគ្គីគ្នា ហើយធ្វើឲ្យគ្រួសារមានភាពល្អប្រសើរ និងរលូនទៅមុខ។ ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចរួមមាន៖

- "សោហ៊ុយដើម្បីរក្សាជីវភាពរួមរស់របស់ប្តី ប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន
- កាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងគ្នាតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធណាម្ខាង បានទទួលបន្ទុក ដោយមានការយល់

---

44 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៧។

45 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧១។

ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរ ពីប្ដី ឬប្រពន្ធម្ខាងទៀតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

– សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម"[46]។

ការកំណត់នូវវិធានដូចខាងលើ ពីព្រោះចង់ឲ្យសហព័ទ្ធទាំងអស់ មានទំនួលខុសត្រូវចំពោះទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលមានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ហើយក៏ជាការគ្រប់គ្រងទ្រព្យសម្បត្តិ និងដាក់បន្ទុកឲ្យភាគីទាំងពីរមានកាតព្វកិច្ច ជួយសហការ និងសាមគ្គីគ្នាទៅវិញទៅមក។

### ២.៧.៣ ៖ ប្រព័ន្ធទ្រព្យសម្បត្តិ ប្ដី ប្រពន្ធ

#### ២.៧.៣.១ ៖ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ដោយហេតុថាទំនាក់ទំនងទ្រព្យសម្បត្តិរវាងសហព័ទ្ធនីមួយៗអាចក្លាយជាចំនុចវិវាទនាថ្ងៃក្រោយ ដូច្នេះហើយការបង្កើតឲ្យមានការបែងចែក ដ៏ច្បាស់លាស់នៅក្នុងច្បាប់អំពីទំនាក់ទំនងទ្រព្យសម្បត្តិជាកត្តាសំខាន់មួយដែលអាចជួយការពារផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាងផងដែរ។ លើសពីនេះទៅទៀតនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិអំពី "កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលអាចធ្វើឡើងមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ ក្នុងករណីស្របតាមខ្លឹមសារនៃសិទ្ធិទាមទារ អាហារកាតព្វកិច្ច និងភាគបម្រុង ហើយមិនប្រាស់ចាកពីប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់បានចែង"[47]។ បើទោះបីជាច្បាប់បានកំណត់អំពីកិច្ចសន្យាទ្រព្យសម្បត្តិនេះក៏ដោយ ប៉ុន្តែការអនុវត្ត ឬ ការប្រើប្រាស់កិច្ចសន្យានេះស្ទើតែគ្មានទាស់តែសោះ ដោយសារតែកត្តាជំនឿចិត្តរបស់សហព័ទ្ធទាំងសងខាង។ "កិច្ចសន្យានេះត្រូវតែធ្វើឡើងជាលាយល័ក្ខណ៍អក្សរ"[48]។

#### ២.៧.៣.២ ៖ ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់

ដើម្បីឲ្យទំនាក់ទំនងនៃទ្រព្យសម្បត្តិរវាងសហ័ទ្ធមានតម្លាភាព និងត្រឹមត្រូវច្បាប់បានបញ្ញត្តិឲ្យមានការបែងចែកទ្រព្យជាពីរប្រភេទគឺ ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។

##### ក.ប្រព័ន្ធទ្រព្យសម្បត្តិរួម

"ទ្រព្យសម្បត្តិរួម គឺជាទ្រព្យរបស់សហព័ទ្ធទាំងពីរ ឬតែម្ខាងដែលមានក្រោយពេលរៀបអាពាហ៍ពិពាហ៍ លើកលែងទ្រព្យសម្បត្តិដែលជា ប្រទានកម្ម សន្តតិកម្ម និង អច្ច័យទាន"[49]។

---

46ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៥។

47ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។

48ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

49 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

"ចំពោះការចាត់ចែង ឬប្រើប្រាស់នៃទ្រព្យសម្បត្តិរួមដែលជាតម្រូវការមិនអាចអាក់ខានបាននោះ មិនត្រូវឲ្យមានការប៉ះពាល់ដល់តម្រូវការជីវភាពប្រចាំថ្ងៃឡើយ"[50]។ ប្រសិនបើមានការមិនយល់ព្រម ទៅលើការប្រើប្រាស់ណាមួយនៃទ្រព្យសម្បត្តិរួម របស់សហព័ទ្ធនោះសហព័ទ្ធម្ខាងទៀតអាចធ្វើការ ដាក់ពាក្យប្តឹងទៅតុលាការ ដើម្បីឲ្យតុលាការធ្វើការសម្រេចលើវិវាទនៃការចាត់ចែងចំពោះការ គ្រប់គ្រងនៃទ្រព្យសម្បត្តិរួមបាន។

### ខ. ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក

យោងតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងអំពីនិយមន័យនៃការ ចែកទ្រព្យសម្បត្តិដោយឡែកដូចតទៅ៖

"ទ្រព្យសម្បត្តិទាំងឡាយណាដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍។ រាល់ទ្រព្យ សម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន នៅក្នុងអំឡុងពេលអា ពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការការចាត់ចែងពីការចាត់ចែងទ្រព្យ សម្បត្តិក្នុងចំណុចទាំងពីរខាងលើ"[51]។

### គ. ការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក

"សហព័ទ្ធមានសិទ្ធិប្រើប្រាស់ ទ្រព្យសម្បត្តិដែលជាទ្រព្យដោយឡែករបស់ខ្លួនទៅតាមតម្រូវ ការ"[52]។ លើសពីនេះទៅទៀត សហព័ទ្ធម្ខាងអាចប្រើប្រាស់អាស្រ័យនៅលើទ្រព្យសម្បត្តិដោយ ឡែករបស់សហព័ទ្ធម្ខាងផងដែរ។ យោងតាមមាត្រា៩៧៧ "សហព័ទ្ធមានសិទ្ធិស្នាក់អាស្រ័យលើ អចលវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែកស្ថិតក្រោមកម្មសិទ្ធរបស់សហព័ទ្ធម្ខាងទៀត ដើម្បីផ្គត់ផ្គង់ ការរស់នៅរបស់គ្រួសារទាំងមូលបើទោះបីជាអចលវត្ថុនោះត្រូវបានសហព័ទ្ធម្ខាងទៀតចាត់ចែងក៏ ដោយក៏សិទ្ធិរស់នៅបន្តទៀតដែរ"[53]។

## ២.៧.៤ ៖ អនុភាពចំពោះអំពើ ឬសកម្មភាពដែលត្រូវលើកលែង និងការហាមឃាត់ ដោយច្បាប់បញ្ញត្តិខ្លះនៃក្រមរដ្ឋប្បវេណី

ច្បាប់បានកំណត់យ៉ាងតឹងរឹង នូវសកម្មភាពមួយចំនួនដែលបានលើកលែង និងហាមឃាត់ លើសកម្មភាពនោះ ដោយសហព័ទ្ធមិនត្រូវធ្វើក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍។ ក្នុងនោះរួម

50 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៤ ចំនុច២។

51 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

52 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៤ ចំនុច១ វាក្យខណ្ឌទី2។

53 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៧។

មានការមិនទទួលខុសត្រូវព្រហ្មទណ្ឌ និងការហាមឃាត់នូវទ្វេរពន្ធភាព ឬការរៀបអាពាហ៍ពិពាហ៍ជាមួយញាតិពន្ធ ប្រសិនបើមានការបំពាននូវគោលការណ៍ទាំងនេះច្បាប់កំណត់ឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ។

### ២.៧.៤.១ ៖ ការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

ជនណាក៏ដោយ ឲ្យតែបានប្រព្រឹត្តបទល្មើស ដែលច្បាប់កំណត់ជននោះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ប៉ុន្តែក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីករណីលើកលែង ចំពោះការប្រព្រឹត្តបទល្មើសតែមិនទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។ តាមក្រមព្រហ្មទណ្ឌក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ថា "មិនអាចដាក់ទោសព្រហ្មទណ្ឌបានទេចំពោះ អំពើលួចទ្រព្យសម្បត្តិ របស់បុព្វញាតិ ឬបច្ឆាញាតិ របស់សហព័ទ្ធ"[54]។ មានន័យថា ការលួចទ្រព្យសម្បត្តិរបស់ឪពុក ម្តាយ ឬប្តីប្រពន្ធមិនត្រូវបានច្បាប់ដាក់ទោសនោះទេ ពីព្រោះគ្រួសារមានអភ័យឯកសិទ្ធិពិសេស ក្នុងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដែលច្បាប់បានគាំពារ។ ក្រៅពីនេះ យើងបានរកឃើញមាត្រា មួយចំនួនដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសតែឲ្យរួចផុតពីការដាក់ខុសត្រូវព្រហ្មទណ្ឌ ដូចជាមាត្រា ៥២៩ និង៥៣៩។

### ២.៧.៤.២ ៖ ការហាមឃាត់ដោយច្បាប់ និងការទទួលខុសត្រូវព្រហ្មទណ្ឌ

ការរៀបអាពាហ៍ពិពាហ៍ គឺត្រូវគោរពទៅតាមឆន្ទៈរបស់ភាគី ដោយមិនប្រកាន់អាយុ វណ្ណៈ ពណ៌សម្បុរ ប៉ុន្តែមានករណីលើកមួយចំនួន និង ច្បាប់បានចែងយ៉ាងច្បាស់ថាហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ឡើយ បើទោះបីជាកើតចេញពីឆន្ទៈរបស់ភាគីក៏ដោយដែលក្នុងនោះរួមមាន៖ ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាពគឺ "បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ"[55]។ មានន័យថា ជនដែលមានជាប់ទំនាក់ទំនងប្តី ប្រពន្ធ ដែលមិនទាន់ដាច់ស្រេច ឬមិនបានលែងលះគ្នាជាស្ថាពរ នោះមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មី បានឡើយដោយប្រកាន់យកគោលការណ៍ប្តី មួយប្រពន្ធមួយ។ "ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែរផ្ទាល់ និងសាខាញាតិពន្ធនៅក្នុងបីថ្នាក់ និងរាប់បញ្ចូលទាំងថ្នាក់ទី៣ ប៉ុន្តែច្បាប់បានលើកលែងករណីដែលសហព័ទ្ធណាម្នាក់បានទទួលបានទទួលមរណភាពនោះសហព័ទ្ធនៅរស់អាចរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងសាខាញាតិពន្ធនៅក្នុងថ្នាក់ទី៣បាន"[56]។

---

54 ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥៥។

55 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៥។

56 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥២។

ដោយឡែកប្រសិនបើ មានការរំលោភបំពានលើសហព័ទ្ធ ដូចជាករណី ទ្វេពន្ធភាព និងការរួមភេទជាមួយញាតិពន្ធក្នុងបីថ្នាក់ សុទ្ធតែជាបទល្មើសព្រហ្មទណ្ឌ ដូចដែលមានចែងក្នុងមាត្រា ៣៥០ មាត្រា៣៥១ និងមាត្រា៣៥២ នៃក្រមព្រហ្មទណ្ឌ។ លើសពីនេះទៅទៀត "ចំពោះការប្រើប្រាស់អំពើហិង្សាទៅលើសហព័ទ្ធ ឬអនីតិសង្វាសជន ក៏ត្រូវបានក្រមព្រហ្មទណ្ឌកំណត់ដាក់ទោសផងដែរ"[57]។

**២.៧.៥ ៖ លក្ខខណ្ឌពិសេសដែលទទួលបាន**

ក្រោយពីការរៀបអាពាហ៍ពិពាហ៍ ជនជាតិបរទេសអាចទទួលបាននូវលក្ខខណ្ឌពិសេសមួយចំនួនដូចជាការទទួលបាននូវសញ្ជាតិខ្មែរ ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីសញ្ជាតិ " ស្ត្រី ឬបុរសដែលយកប្តី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រីឬបុរសនោះរស់នៅជាមួយរយៈពេលបីឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល១២(ដប់ពីរ)ខែពេញលេញនៅព្រះរាជាណាចក្រកម្ពុជា"[58]។ ថ្វីបើច្បាប់បានកំណត់ថាសាមីខ្លួនជនបរទេសទាមទារបានបានសញ្ជាតិខ្មែរក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ក្តីតែសាមីខ្លួនជនបរទេសត្រូវតែមាន "គំនិត មាយាទ និងសីលធម៌ល្អ ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទបជ្ជឹមណាមួយ ត្រូវមានលំនៅដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ និងត្រូវចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងត្រូវយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ មានបញ្ញា និងកាយសម្បទាដែលមិននាំឲ្យមានគ្រោះថ្នាក់ ឬនាំឲ្យមានបន្ទុកដល់ជាតិ"[59]។ រីឯបែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។ ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។ ជាការកត់សម្គាល់ច្បាប់បានបញ្ជាក់ថា នៅក្នុងករណីនេះ ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារតែការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសឡើយ។

57 ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២២២។

58 ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/១០៩៦/៣០,២០ សីហា ១៩៩៦, មាត្រា១១ កថាខណ្ឌ១។

59 ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/១០៩៦/៣០,២០ សីហា ១៩៩៦, មាត្រា១២។

# ជំពូកទី៣

# ការលែងលះ និងអានុភាពនៃការលែងលះរវាងពលរដ្ឋខ្មែរ និងជនបរទេស

# ជំពូកទី៣
# ការលែងលះ និងអនុភាពនៃការលែងលះរវាងពលរដ្ឋខ្មែរ និងជនបរទេស

## ៣.១ ៖ អត្ថន័យនៃការលែងលះ

អាពាហ៍ពិពាហ៍ កើតឡើងដោយការព្រមព្រៀងរវាងបុរស និងនារី តែមិនមានន័យថាភាគីមានសេរីភាពក្នុងការបង្កើតទៅតាមចិត្តចង់នោះទេគឺត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់បានអនុញ្ញាត និងត្រូវគោរពទៅតាមទម្រង់ក្នុងការរៀបអាពាហ៍ពិពាហ៍ ទើបអាចក្លាយទៅជាសហព័ទ្ធនឹងគ្នា។ យ៉ាងណាមិញ អាពាហ៍ពិពាហ៍ មួយមិនប្រាកដថាបានរលូន និងគង់វង្សនោះទេ តែងតែមានការបែកបាក់ទៅវិញ ចំពោះការបញ្ចប់ទំនាក់ទំនងសហព័ទ្ធមិនមែនអាចធ្វើបានដោយសេរីនោះទេគឺលុះត្រាតែមានការចូលអន្តរាគមន៍ពីស្ថាប័នតុលាការ ពីព្រោះ ការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ឬការលែងលះបណ្តាលឲ្យប៉ះពាល់យ៉ាងខ្លាំងចំពោះទំនាក់ទំនងបុគ្គលនិងសង្គម។ ចំពោះការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ គឺមានភាពដូចគ្នាទៅនឹងការលែងលះ រវាងពលរដ្ឋខ្មែរ និងជនបរទេសដែរ។

### ៣.១.១ ៖ ការលែងលះតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

នៅឆ្នាំ១៩៨៩ យើងសង្កេតឃើញមានច្បាប់ស្តីពីពាហ៍ពិពាហ៍ និងគ្រួសារ ដែលក្នុងនោះក៏បានបញ្ញត្តិផងដែរនូវវិធាននៃការលែងលះ។ចំពោះនិយមន័យនៃការលែងលះគ្នាក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានកំណត់ថា ការលែងលះគ្នា គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់[60]។ នៅក្នុងច្បាប់ដដែលក៏បានផ្តល់ឱ្យប្តីប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តផងដែរ [61] តែបើមិនស្ម័គ្រចិត្តទេ គឺមានមូលហេតុដែលច្បាប់នោះបានអនុញ្ញាត និងកំណត់ឱ្យប្តី ឬ ប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន[62] ។

គួរបញ្ជាក់ថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ត្រូវបាននិរាករណ៍ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីស្ទើតែទាំងស្រុងហើយ ប៉ុន្តែនៅតែមាត្រាមួយចំនួនប៉ុណ្ណោះដែលនៅជាធរមាន។ ជាក់ស្តែងត្រង់មាត្រា៧៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានចែងថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបាត់បង់អានុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែបញ្ញត្តិនៃមាត្រា

60 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៣៨

61 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៤០

62 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៣៩

៧៦ មាត្រា៧៧ និងបញ្ញត្តពីមាត្រា៧៩ ដល់មាត្រា៨១ នៃច្បាប់នេះនៅតែមានអានុភាពអនុវត្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តរហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់នេះ។

### ៣.១.២ ៖ អត្ថន័យនៃការលែងលះតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់គន្ថីទី៧ និងគន្ថីទី៨ ដែលក្នុងនោះ ការលែងលះ ក៏បានបញ្ញត្តិត្រង់ជំពូកទី៣(អាពាហ៍ពិពាហ៍) ផ្នែកទី៤(ការលែងលះគ្នា)។ ដោយឡែកក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានចែងយ៉ាងជាក់លាក់អំពីនិយមន័យនៃការលែងលះ ដូចច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារនោះទេ តែមានចែងអំពីមូលហេតុនៃការលែងលះ ការបែងចែកទ្រព្យសម្បត្តិ ការបែងចែកកូន និងនីតិវីធីនៃការលែងលះគ្នា។

## ៣.២ ៖ ប្រភេទនៃការលែងលះ

### ៣.២.១ ៖ ការលែងលះដោយការព្រមព្រៀង

តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ត្រូវបានបើកសិទ្ធិសេរីភាពចំពោះភាគីក្នុងការលែងលះគ្នាតាមការព្រមព្រៀង ឬតាមពាក្យសុំ ដោយបានបញ្ញត្តិនៅក្នុងមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី ដែលទទួលស្គាល់នូវសេរីភាពរបស់ភាគីក្នុងការរំលាយអាពាហ៍ពិពាហ៍ ឲ្យតែមានឆន្ទៈក្នុងការលែងលះគ្នា[63] ដោយមិនពិចារណាទៅលើមូលហេតុនៃការលែងលះដែលបានកំណត់ដោយច្បាប់នោះទេ។ ហេតុនេះការព្រមព្រៀងរបស់ភាគី គឺជាចំណុចសំខាន់ដែលតុលាការត្រូវធ្វើការពិចារណាថាតើភាគីទាំងសងខាងពិតជាមានបំណងចង់រំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍មែន ឬមិនមែន។

ការលែងលះតាមការព្រមព្រៀង ការទាមទារចម្បង គឺការលែងលះ ប៉ុន្តែភាគីក៏អាចទាមទារនូវចំណុចផ្សេងផងដែរដូចជា ការបែងចែកទ្រព្យសម្បត្តិ ការកំណត់អំពីសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូនជាអាទិ៍។ ការលែងលះដោយការព្រមព្រៀង តែងតែធ្វើកិច្ចព្រមព្រៀងមួយ ដែលបញ្ជាក់ពីឆន្ទៈនៃការព្រមព្រៀងគ្នាលែងលះ ហើយដាក់ពាក្យសុំលែងលះ ដោយភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងនោះ។ ការព្រមព្រៀងគ្នាលែងលះ ត្រូវធ្វើនៅតុលាការទើបមានអានុភាព ពីព្រោះការលែងលះមានអានុភាពដោយដីកាសម្រេចឲ្យលែងលះប្រសិនបើតុលាការយល់ឃើញថាភាគីមានឆន្ទៈពិតប្រាកដក្នុងការលែងលះ។ចំពោះការបែងចែកទ្រព្យសម្បត្តិ អាចធ្វើឡើងតាមការពិភាក្សាគ្នា ប៉ុន្តែក្នុងករណី ភាគីមិនអាចពិភាក្សាគ្នាអំពីការបែងចែកទ្រព្យ ភាគីអាចទាមទារឲ្យតុលាការបែងចែកទ្រព្យនៅក្នុងពាក្យសុំលែងលះបាន ។ ចំណែកឯ ការទាមទារឲ្យកំណត់សោហ៊ុយចាំបាច់ដើម្បី

63 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩ កថាខណ្ឌ១

ចិញ្ចឹមកូន អាចធ្វើឡើងតាមការពិភាក្សាគ្នា ប៉ុន្តែក្នុងករណីភាគីមិនអាចពិភាក្សាគ្នាកំណត់អំពីសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូនបានអាចទាមទារ ឲ្យតុលាការកំណត់សោហ៊ុយចាំបាច់ ដើម្បីចិញ្ចឹមកូននៅក្នុងពាក្យសុំលែងលះបាន[64]។

### ៣.២.២ ៖ ការលែងលះដោយមិនមានការព្រមព្រៀង

ការលែងលះដោយមិនមានការព្រមព្រៀង គឺជាការទាមទារឱ្យលែងលះដោយឆន្ទៈរបស់ភាគីម្ខាងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុដែលកំណត់ដោយច្បាប់ ហេតុនេះក្នុងករណីមូលហេតុពុំត្រូវតាមផ្លូវច្បាប់ទេ នោះតុលាការមិនអាចសម្រេចឲ្យលែងលះគ្នាបានទេ ។

ភាគីទាមទារឲ្យមានការលែងលះ ត្រូវទទួលបន្ទុកបញ្ជាក់អំពីអង្គហេតុនីមួយៗដែលជាមូលហេតុនៃការលែងលះ ដើម្បីឲ្យតុលាការសម្រេចឲ្យលែងលះ ហេតុនេះ យើងសង្កេតឃើញថា ការលែងលះគ្នាដោយការព្រមព្រៀង គឺមានភាពងាយស្រួល និងមិនស្មុគស្មាញដូចជាការលែងលះដោយគ្មានការព្រមព្រៀងនោះទេ។ រួមជាមួយគ្នាផងដែរ ចំពោះការទាមទារក៏បានច្រើនចំណុចជាងការលែងលះដោយការព្រមព្រៀង ដូចជា ការទាមទារអាហារកិច្ច ការទាមទារសំណងនៃការខូចខាតដែលចំណុចនេះ មិនអាចទាមទារបាននៅក្នុងការលែងលះដោយការព្រមព្រៀង។

ចំពោះមូលហេតុនៃការលែងលះ ត្រូវបានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា៩៧៨ ដែលផ្តើមចេញពីមាត្រានេះ យើងអាចបែងចែកមូលហេតុនៃការលែងលះជាពីរប្រភេទ គឺមូលហេតុជាក់លាក់ និង មូលហេតុមិនជាក់លាក់ ។

- មូលហេតុជាក់លាក់៖

ក្នុងមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់កថាខណ្ឌទី១ ចាប់ពីចំណុចក ដល់ចំណុចឃ គឺជាមូលហេតុដែលមានភាពច្បាស់លាស់ និងជាក់លាក់។

- ការប្រព្រឹត្តអំពើផិតក្បត់៖ ជាអំពើដែលសហព័ទ្ធម្ខាង បានលួចលាក់មានអ្នកណា ផ្សេងទៀត ក្រៅពីសហព័ទ្ធរបស់ខ្លួនដែលកំពុងស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬចំណងអាពាហ៍ពិពាហ៍ចាស់មិនទាន់រលត់ជាស្ថាពរ នោះសហព័ទ្ធម្ខាងអាចទាមទារឲ្យលែងលះបាន។

64 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៨០

- ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ៖ ជាការមិនទទួលខុស ត្រូវក្នុងការរួមរស់ សហការគ្នាទៅវិញទៅមក និងគ្មានឆន្ទៈក្នុងការរស់នៅបន្ត ជាមួយគ្នាទៀត នោះសហព័ទ្ធម្ខាងអាចទាមទារឲ្យលែងលះបាន។
- ករណីមិនដឹងសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ៖ ក្នុងចំណោមសហព័ទ្ធ ទាំងពីរមានសហព័ទ្ធ ណាម្ខាងបានចាកចោលពីលំនៅដ្ឋានរបស់ខ្លួន ដោយមិនបានប្រាប់ពីមូលហេតុច្បាស់លាស់អំពីការចាកចេញនោះ ឬសហព័ទ្ធម្ខាងទៀតមិនបាន ដឹងអំពីដំណឹងថាសហព័ទ្ធរបស់ខ្លួនស្លាប់ ឬរស់អស់រយៈពេលជាង០១ឆ្នាំ នោះ សហព័ទ្ធម្ខាងអាចទាមទារឲ្យលែងលះបាន។
- ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង០១ឆ្នាំ៖ ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង០១ឆ្នាំ គឺជាការរស់នៅបែកផ្ទះគ្នាដោយ មិនរស់នៅជាមួយគ្នាដូចប្តី ប្រពន្ធធម្មតា គឺវាផ្ទុយនឹងគោលបំណងក្នុងការរៀប អាពាហ៍ពិពាហ៍ ដូចនេះសហព័ទ្ធម្ខាងអាចទាមទារឲ្យលែងលះបាន។
- មូលហេតុមិនជាក់លាក់ ៖

ក្រៅពីមូលហេតុកំណត់ជាក់លាក់នីមួយៗខាងលើ ការលែងលះ អាចធ្វើទៅបានដោយផ្អែកលើមាត្រា៩៧៨ដដែល កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី។ បញ្ញត្តិនេះចែងថា "ក្នុងករណីមានមូលហេតុផ្សេងទៀត ដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានវិញបាន ត្រូវចាត់ទុកជាមូលហេតុនៃការលែងលះ"[65]។ ដូចនេះ យើងអាចកំណត់បានថា មូលហេតុនៃការលែងលះដែលមានបញ្ញត្តិក្នុងមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ង គឺជាមូលហេតុមិនជាក់លាក់ ពោលគឺជាមូលហេតុដែលត្រូវបានផ្អែកលើករណីនីមួយៗទៅតាមភាពជាក់ស្តែង។

បន្ថែមពីនេះទៅទៀត ទោះបីជាមានមូលហេតុនៃការលែងលះ ដូចដែលបានលើកឡើងខាងលើរួចមកហើយក៏ដោយ ក៏តុលាការអាចច្រានចោលការទាមទារលែងលះគ្នាបានដែរ ប្រសិនបើតុលាការពិនិត្យឃើញមានស្ថានភាពដូចខាងក្រោម៖

- បើការលែងលះនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬបើការលែងលះនឹងបណ្តាលឲ្យមានការឈឺចាប់មិនអាចទ្រទ្រង់បាន។

65 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ ចំណុច១

- ក្នុងករណីដូចបានកំណត់ក្នុងមូលហេតុដូចក្នុងចំណុច ឃ ឬ ង បើការទាមទារលែងលះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឲ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិការ និងជួយសង្គ្រោះចំពោះសហព័ទ្ធ [66]។

## ៣.៣ ៖ នីតិវិធីក្នុងការលែងលះ

ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលបានរៀបអាពាហ៍ពិពាហ៍ នៅប្រទេសកម្ពុជា គឺគោរពតាមច្បាប់នៃប្រទេសកម្ពុជា ដូចនេះ ការលែងលះរវាងពលរដ្ឋខ្មែរ និងជន បរទេស ក៏ត្រូវគោរពតាមបែបបទ និងទម្រង់គតិយុត្តិនៃប្រទេសកម្ពុជាផងដែរ។

### ៣.៣.១ ៖ ជនដែលមានសិទ្ធិក្នុងការលែងលះ

"ច្បាប់នៃប្រទេសកម្ពុជា ប្តី និងប្រពន្ធ មានសិទ្ធិក្នុងការដាក់ពាក្យសុំលែងលះគ្នាបាន"[67]។ ដូច្នេះ បញ្ជាក់ឲ្យឃើញថា ចំពោះការលែងលះគ្នា ចំណុចដែលសំខាន់បំផុត គឺភាគីនៃការលែងលះត្រូវតែជា ប្តី និង ប្រពន្ធ ដែលជាម្ចាស់នៃបណ្តឹង ក្រៅពីសហព័ទ្ធ ជនដទៃទៀតមិនអាចក្លាយជា ភាគីនៃបណ្តឹង បានឡើយ ដោយសារតែភាគី គឺជាប្រធាននៃបណ្តឹង ដូចនេះភាគីត្រូវចូលរួមគ្រប់នីតិវិធីនៃការលែងលះ។

### ៣.៣.២ ៖ សមត្ថកិច្ចដែលមានសិទ្ធិក្នុងការផ្សះផ្សា និងលែងលះ

#### ក . សមត្ថកិច្ចនៅអាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់)

ជាទូទៅភាគីអាចដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចឃុំសង្កាត់ ដើម្បីធ្វើការលែងលះគ្នាដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៩៨២ បានចែងយ៉ាងច្បាស់ថាភាគីអាច ដាក់ពាក្យបណ្តឹងសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំ សង្កាត់ខាងលំនៅឋាន ឬ ទីសំណាក់របស់ សហព័ទ្ធចុងចម្លើយបាន។ "បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវ កំណត់តាមលំនៅឋានចុងក្រោយ" [68] ។ ក្នុងករណីដែលមានការដាក់ពាក្យសុំលែងលះគ្នា មកដល់ "ក្រុមប្រឹក្សាឃុំ សង្កាត់ នោះក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឲ្យសះជាគ្នាបានក្នុងអំឡុងពេល១៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ"ផ្ទុយមកវិញ "បើមិនអាចបញ្ចុះបញ្ចូលឲ្យសះ ជាគ្នាបានទេត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅ

66 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ ចំណុច២

67 ឥន ឌឿន ២០១៣, នីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ទំព័រ២១០

68 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១០ ចំណុច២ កថាខណ្ឌ២

តុលាការជាបន្ទាន់”[69]។ក្នុងន័យនៃមាត្រានេះ សបញ្ជាក់ឲ្យឃើញថា ក្រុមប្រឹក្សាឃុំសង្កាត់(មេឃុំ ចៅសង្កាត់) មានតែសិទ្ធិក្នុងការផ្សះផ្សានៅពេលដែលមានពាក្យបណ្ដឹងចូលមកប៉ុណ្ណោះ ផ្ទុយមកវិញគ្មានសិទ្ធិអំណាចក្នុងការសម្រេចឲ្យលែងលះគ្នានោះទេ។ ប្រសិនបើការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចធ្វើឲ្យមានការសះជាវិញក្នុងអំឡុងពេល ១៥ថ្ងៃបន្ទាប់ពី ទទួលបានពាក្យសុំនោះត្រូវបញ្ជូនពាក្យសុំនោះទៅតុលាការជាបន្ទាន់។

### ខ. សមត្ថកិច្ចនៅតុលាការ (សាលាដំបូង រាជធានី ខេត្ត)

បន្ទាប់ពីទទួលបានពាក្យសុំលែងលះគ្នា ពីក្រុមប្រឹក្សាឃុំ សង្កាត់មក តុលាការមានសមត្ថកិច្ចពេញលេញ ក្នុងការសម្រេចសេចក្ដី។ តុលាការចំណាត់ការតាមនីតិវិធី ដោយការបែងចែករឿងក្ដីតាមលំដាប់ដែលបានកំណត់ជាមុន នូវឈ្មោះចៅក្រម បន្ទាប់ពីពាក្យសុំបានមកដល់ដៃរបស់ចៅក្រមទទួលបន្ទុក នោះចៅក្រមទទួលបន្ទុកត្រូវចាប់ផ្ដើមចំណាត់ការលើរឿងក្ដី។

ចំណាត់ការលើរឿងក្ដីនោះ រួមមាន៖

- ការពិនិត្យពាក្យបណ្ដឹង និងពាក្យសុំ៖

ចៅក្រមដែលជាតួអង្គតុលាការ ត្រូវធ្វើការពិនិត្យទៅពាក្យបណ្ដឹង ឬពាក្យសុំនោះថាត្រូវតាមទម្រង់ដែលច្បាប់បានកំណត់ ឬនៅ? "ចំណុចដែលត្រូវសរសេរនោះរួមមាន៖ អត្តសញ្ញាណរបស់ភាគី ខ្លឹមសារនៃសាលក្រម ឬដីកាសម្រេច និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ”[70]។ ក្នុងករណីដែលចៅក្រមទទួលបន្ទុកបានពិនិត្យឃើញនូវចំណុចខ្វះចន្លោះនូវមូលហេតុខាងលើ នោះចៅក្រមអាចចេញដីកាបង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាត ដោយកំណត់អំឡុងពេលសមរម្យដើម្បី ឲ្យធ្វើការកែតម្រូវ ប៉ុន្តែបើមិនកែតម្រូវទេ ចៅក្រមអាចលើកពាក្យបណ្ដឹង ឬពាក្យសុំនោះចោលដោយដីកាសម្រេច[71]។

## ៣.៣.៣ ៖ ចំណាត់ការក្នុងការលែងលះ

បន្ទាប់ពីមើលលើពាក្យបណ្ដឹង ឬពាក្យសុំ ត្រូវតាមទម្រង់ចប់សព្វគ្រប់ហើយ ចៅក្រមទទួលបន្ទុកជាអ្នកកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដើម្បីឲ្យគូភាគីនៃអាពាហ៍ពិពាហ៍អាចអះអាងនូវចំណុចវិវាទ និងអាចឈានដល់ការសម្រេចសេចក្ដីបាន។

---

69 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨២ កថាខណ្ឌ២

70 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា៧៥

71 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា៧៨

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ មានតែចំពោះរឿងក្ដីលែងលះតាមពាក្យបណ្ដឹង ប៉ុណ្ណោះ។

### ក. នីតិវិធីត្រៀមទាញហេតុផលតាមពាក្យបណ្ដឹង និងពាក្យសុំ

រឿងក្ដីលែងលះតាមពាក្យបណ្ដឹង គឺឈរលើមូលដ្ឋាននៃមូលហេតុលែងលះតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមិនមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ វានឹងនាំឲ្យចៅក្រមពិបាកកំណត់ចំណុចវិវាទ នៃរឿងក្ដីដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់ និងអាចឈានដល់ការសម្រេចសេចក្ដី ឲ្យមានការលែងលះ[72]។

ផ្ទុយមកវិញ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ត្រង់មាត្រា១០៣ មិនបានបញ្ជាក់ឲ្យច្បាស់ ថា ការលែងលះដោយព្រមព្រៀង ឬពាក្យសុំមិនចាំបាច់ក្នុង ការឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការ ទាញហេតុផលនោះទេ ប៉ុន្តែបានប្រើពាក្យថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវ រៀបចំនូវសេចក្ដីអះអាងរបស់ភាគីបំភ្លឺ នូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដី ដូច្នេះយើងអាចសន្និដ្ឋានបានថា ក្នុងរឿងក្ដីលែងលះដោយការព្រមព្រៀង គឺមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការ ទាញហេតុផលនោះទេ ពីព្រោះភាគីបានព្រមព្រៀងយល់ស្របគ្នាក្នុងការលែងលះ ម៉្យាងវិញទៀត ការលែងលះដោយការព្រមព្រៀង ភាគីបានបង្ហាញនូវឆន្ទៈថាលែងលះតាមការព្រមព្រៀងរួចហើយ ដូចនេះ វាពុំមានអ្វីចាំបាច់ដើម្បីកំណត់ចំណុចវិវាទទៀតឡើយ។ ប្រសិនបើឆ្លងកាត់"នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នោះតុលាការត្រូវធ្វើឡើងនៅ ការបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន។ កាលបរិច្ឆេទនៃនីតិវិធីសម្រាប់ការទាញហេតុផលមិនចាំបាច់បើកជាសាធារណៈទេ ប៉ុន្តែតុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន [73] "។ "នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតុលាការត្រូវសាកល្បងធ្វើការផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ" [74] ។ ប្រសិនបើមិនមានការផ្សះជាទេ នោះតុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅគ្រប់កាលបរិច្ឆេទនីមួយៗ[75]។ នៅក្នុងកំណត់ហេតុនេះផងដែរ

72 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១០៣

73 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១០៥

74 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១០៤

75 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១០៩

ក្រឡាបញ្ជីត្រូវកត់ត្រានូវ ចំណុច ដូចជា សញ្ញាណរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី ឈ្មោះរបស់ភាគី ពេលវេលា និងទីកន្លែង បន្ទាប់ពីធ្វើកំណត់ហេតុរួចហើយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានធ្វើនោះ[76]។

**ខ. នីតិវិធីទាញហេតុផលផ្ទាល់មាត់**

បន្ទាប់ពីធ្វើការត្រៀមទាញហេតុផលចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម[77]។

នៅក្នុងរឿងក្តីលែងលះតាមពាក្យបណ្តឹង ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ប៉ុន្តែត្រូវធ្វើជាអសាធារណៈវិញ ប្រសិនបើភាពជាសាធារណៈនេះធ្វើឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ[78] ហើយវាមានចំណុចជាច្រើនដែលពាក់ព័ន្ធជិតស្និទ្ធទៅនឹងការសម្ងាត់នៃជីវភាពរស់នៅរបស់បុគ្គលឯកជន។ នៅក្នុងរឿងក្តីលែងលះតាមពាក្យសុំ "តុលាការអាចចេញដីកាសម្រេច ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ក្នុងករណីបើមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេតុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថា ចាំបាច់បាន។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន"[79]។ "តុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធី ទាញហេតុផលដោយផ្ទាល់មាត់នៅគ្រប់កាលបរិច្ឆេទនីមួយៗ"[80]។ នៅក្នុងកំណត់ហេតុនេះផងដែរ ក្រឡាបញ្ជី ត្រូវកត់ត្រានូវចំណុចដូចជា សញ្ញាណរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី ឈ្មោះរបស់ភាគី ពេលវេលា និងទីកន្លែង ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ ឬ អសាធារណៈ និងឈ្មោះតំណាងអយ្យការដែលបានចូលរួមប្រសិនបើមាន បន្ទាប់ពីធ្វើកំណត់ហេតុរួចហើយប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានធ្វើនោះ[81]។

---

76 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១១០
77 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១១៣
78 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១១៥
79 ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា២៨
80 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១១៧
81 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១១៨

ចំណាំ៖ ជាគោលការណ៍តំណាងអយ្យការក៏អាចមានវត្តមាននៅក្នុងរឿងក្តីលែងលះបានផងដែរ ប្រសិនបើយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ[82]។

### ៣.៣.៤៖ ការប្រកាសសេចក្តីសម្រេច

ប្រភេទនៃការសម្រេចសេចក្តី របស់តុលាការ គឺមានសាលក្រម និងដីកាសម្រេច។ សាលក្រម គឺជាការសម្រេចសេចក្តី ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់។ ចំណែកឯ ដីកាសម្រេច គឺជាការសម្រេចសេចក្តីដោយតុលាការ ឬចៅក្រមធ្វើការសម្រេចសេចក្តីដោយពុំឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម[83]។

#### ក. សាលក្រមលែងលះ

សេចក្តីសម្រេចក្នុងរឿងក្តីលែងលះតាមពាក្យបណ្តឹង ចៅក្រមត្រូវចេញសាលក្រម ដែលត្រូវមានខ្លឹមសារដូចជា៖ តុលាការ ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ អង្គហេតុ និងចំណុចវិវាទ សំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ដោយមានចុះហត្ថលេខាលើសាលក្រមនោះ[84]។ សាលក្រមនឹងមានអនុភាពដោយការប្រកាស[85] ចំពោះការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ខែ គិតចាប់ពីថ្ងៃដែលមានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈផ្សេងទៀត នោះនឹងមានភាពអូសបន្លាយពេល[86]។ ប្រសិនបើភាគីណាមួយមិនសុខចិត្តនឹងសាលក្រមនេះ ភាគីនោះអាចដាក់បណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ ខែ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីសាលក្រមនោះ[87]។

#### ខ. ដីកាសម្រេចលែងលះ

សេចក្តីសម្រេចលែងលះតាមការព្រមព្រៀង ចៅក្រមត្រូវចេញដីកាសម្រេច ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថ

---

82 ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងឋានៈបុគ្គល, មាត្រា៤

83 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១៧៩

84 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១៨៩

85 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១៨៦

86 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា១៨៧

87 ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦, មាត្រា២៦៤

លេខាលើដីកាសម្រេចនោះ[88]។ ប្រសិនបើភាគីណាមួយមិនសុខចិត្តនឹងដីកាសម្រេចនេះ ភាគីនោះអាចដាក់បណ្តឹងជំទាស់ក្នុងរយៈ ពេល ០២ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ[89]។

## ៤.១ ៖ អនុភាពក្រោយការលែងលះចំពោះសហព័ទ្ធ

នៅពេលដែលមានការប្រកាសសេចក្តីសម្រេចឲ្យធ្វើការលែងលះអនុភាពនៃការរំលាយចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធទាំងពីរនឹងត្រូវរលត់។ ការរំលាយចំណងអាពាហ៍ពិពាហ៍នឹងធ្វើឲ្យមានការកាត់ផ្តាច់នូវទំនាក់ទំនងសហព័ទ្ធ ទ្រព្យសម្បត្តិ និងញាតិ ។

### ៤.១.១ ៖ ការផ្តាច់ចំណងសហព័ទ្ធ

ការផ្តាច់ចំណងអាពាហ៍ពិពាហ៍ ឬលែងលះ ធ្វើឲ្យចំណងសហព័ទ្ធត្រូវបានរលត់ នៅពេលដែលមានសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ ប៉ុន្តែចំពោះ "ប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូល ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន" [90] ។ ទោះបីជាមានការកាត់ផ្តាច់ចំណងប្តី ប្រពន្ធ ហើយក៏ដោយក៏នារីពុំត្រូវឲ្យមានការរៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀតទេ ប្រសិនបើមិនទាន់ផុតរយៈពេល ១២០ថ្ងៃគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ផ្ទុយមកវិញបើនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ហើយបានសម្រាលកូន ឬចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត[91] នោះនារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយពុំចាំបាច់រង់ចាំរយៈពេល ១២០ថ្ងៃ។

### ៤.១.២ ៖ ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ

ទំនាក់ទំនងញាតិពន្ធ គឺកើតឡើងដោយសារចំណងអាពាហ៍ពិពាហ៍ ដូចនេះ ទំនាក់ទំនង ញាតិពន្ធក៏ត្រូវបានបញ្ចប់ដោយការលែងលះផងដែរ ប៉ុន្តែករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬបានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ[92]។ ចំពោះ សហព័ទ្ធដែលនៅរស់រៀបអាពាហ៍ពិពាហ៍ម្តងទៀត នោះទំនាក់ទំនង

88 ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៣៥

89 ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៤០

90 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨១

91 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥០

92 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨១

ញាតិជាមួយនឹងញាតិរបស់សហព័ទ្ធថ្មីនឹងកើតឡើង ដែលធ្វើឲ្យទំនាក់ទំនងញាតិពន្ធមុន និងក្រោយមានភាព ស្មុគស្មាញ ដូច្នេះទើបទំនាក់ទំនងញាតិត្រូវបានកាត់ផ្តាច់ដោយស្វ័យប្រវត្តិតាមរយៈការរៀបអាពាហ៍ពិពាហ៍ថ្មី។ ប៉ុន្តែប្រសិនបើក្រោយពេលដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព នោះទំនាក់ទំនង ញាតិពន្ធត្រូវរលត់ ឬមិនរលត់ទៅតាមការបង្ហាញឆន្ទៈរបស់ជននោះ (ករណីមិនរៀបអាពាហ៍ពិពាហ៍ថ្មី)។

### ៤.១.៣ ៖ ការទទួលបានអាហារកិច្ច

នៅពេលលែងលះ ភាគីដែលគ្មានកំហុសអាចទាមទារឲ្យមានការបង់អាហារកិច្ចចំពោះ ខ្លួនបាន ដោយយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មាត្រា៧៦ បានទទួលស្គាល់ការទាមទារអាហារកិច្ចចំពោះអតីតសហព័ទ្ធដោយការទាមទារអាហារកិច្ចត្រូវបានទទួលស្គាល់ នៅក្នុងករណីមានការលែងលះគ្នា ហើយភាគីនោះគ្មានកំហុស និងខ្វះខាតក្នុងជីវភាពរស់នៅអាចស្នើសុំអាហារកិច្ចពីភាគី ម្ខាងទៀតបាន។ ចំពោះការបង់អាហារកិច្ច ត្រូវព្រមព្រៀងតាមឆន្ទៈរបស់គូភាគី ប្រសិនបើ គូភាគីទាំងសងខាងមិនឯកភាពនោះ តុលាការត្រូវជួយសម្រេចសេចក្តី។

ផ្ទុយមកវិញ ប្រសិនបើជនដែលបានទទួលអាហារកិច្ច បានរៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀត នោះភាគីដែលបានទទួល នឹងគ្មានសិទ្ធិក្នុងការទទួលបានអាហារកិច្ចបន្តទៀតឡើយ[93]។

ចំណាំ៖ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបាននិរាករណ៍ចោលនូវបញ្ញត្តមួយចំនួន ប៉ុន្តែចំពោះបញ្ញត្តត្រង់មាត្រានេះ នៅមានអនុភាពអនុវត្ត។

ការទទួលបានអាហារកិច្ចចំពោះកូនវិញ ក្រោយពេលមានការលែងលះ ឪពុក ឬម្តាយ ត្រូវពិភាក្សាគ្នា ក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ហើយមានករណីកិច្ចក្នុងការទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន។ ប៉ុន្តែប្រសិនបើ ការពិភាក្សានោះមិនបានសម្រេច នោះតុលាការត្រូវកំណត់អំពីការចូលជួប ការប្រាស្រ័យទាក់ទង និងបន្ទុកសោហ៊ុយ តាមរយៈការស្នើសុំរបស់ភាគី។ ចំពោះការបែងចែកប្រាក់សោហ៊ុយក្នុងការ បីបាច់ថែរក្សាដើម្បីចិញ្ចឹមកូនត្រូវគិតទៅលើស្ថានភាពនៃជីវភាពរស់នៅ និងស្ថានភាពសេដ្ឋកិច្ច របស់ភាគីទាំងសងខាង[94]។

93 ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩, មាត្រា៧៦

94 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤០

## ៤.២ ៖ អានុភាពចំពោះការបែងចែកទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិ នៅពេលមានការលែងលះគ្នា តែងតែមានការធ្វើទៅតាមបីរបៀប ដូចជា ការបែងចែកទ្រព្យតាមកិច្ចសន្យា តាមការព្រមព្រៀង និងតាមតុលាការ។

### ៤.២.១ ៖ ការបែងចែកទ្រព្យតាមកិច្ចសន្យា

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបើកសិទ្ធិឲ្យគូភាគី មានសិទ្ធិក្នុងការធ្វើកិច្ចសន្យាកំណត់អំពី អំពីទ្រព្យសម្បត្តិ ប្ដី ប្រពន្ធ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន។ ផ្ទុយមកវិញ ប្រសិនបើ មិនបានធ្វើកិច្ចសន្យាប្ដី ប្រពន្ធទេ នោះត្រូវបែងចែកតាមច្បាប់កំណត់[95]។ ដូចនេះ យើងសង្កេត ឃើញថា នៅពេលលែងលះគ្នា ដោយមានការកំណត់ទ្រព្យសម្បត្តិតាមកិច្ចសន្យាមានការ ងាយ ស្រួល និងមិនស្មុគស្មាញដូចការកំណត់ទ្រព្យសម្បត្តិតាមច្បាប់ ដោយភាគីទាំងពីរបានចុះ បញ្ជី ទ្រព្យសម្បត្តិថា ទ្រព្យសម្បត្តិណាជាទ្រព្យរួម ទ្រព្យសម្បត្តិណាជាទ្រព្យដោយឡែករួចហើយ។

### ៤.២.២ ៖ ការបែងចែកទ្រព្យតាមការព្រមព្រៀងរបស់ភាគី

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់មាត្រា៩៨០ កថាខណ្ឌ១ បានចែងថា ក្នុងករណីដែលប្ដី ប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំង សងខាង [96]។ ដូចនេះ ប្រសិនបើមានការពិភាក្សាគ្នា និងព្រមព្រៀងលើការបែងចែកលើប្រភេទ និង តម្លៃនៃទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករួចហើយ នោះធ្វើឲ្យតុលាការងាយស្រួលក្នុង ការ សម្រេចសេចក្ដី។

### ៤.២.៣ ៖ ការបែងចែកទ្រព្យដោយតុលាការ

ចំពោះទ្រព្យសម្បត្តិប្ដី ប្រពន្ធ បានបែងចែកជា ទ្រព្យសម្បត្តិរួម និងទ្រព្យដោយឡែករបស់ ប្ដី និងប្រពន្ធ។ ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀប អាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យ សម្បត្តិដែលបានកំណត់ក្នុងចំណុចទាំងពីរនេះ[97]។ ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្ដីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែ

---

95 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩

96 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០

97 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២

ទ្រព្យសម្បត្តិដែលមានចែងក្នុងចំណុចខ និងគ នៃមាត្រា៩៧២[98]។ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ នោះត្រូវបែងចែកទ្រព្យសម្បត្តិតាមចំណុចនីមួយៗ ដូចត្រូវបានកំណត់ដោយច្បាប់។ សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។ ក្រៅពីទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិរួម សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១២/ នៃទ្រព្យសម្បត្តិរួម[99]។ ផ្ទុយមកវិញ ប្រសិនបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃ ការបរិច្ចាគរបស់ភាគីនីមួយៗ ការថែរក្សា ឬការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍[100]។

ដូចនេះ បើមានការលែងលះ ចំពោះទ្រព្យដោយឡែក គឺបែងចែកទៅឲ្យភាគីវិញរៀងៗខ្លួន ចំណែកឯទ្រព្យរួមវិញ គឺបែងចែកស្មើគ្នា ១/២ នៃទ្រព្យនោះ ប៉ុន្តែមានករណីមួយចំនួនដូចបានរៀបរាប់ខាងលើ នោះភាគីម្ខាងអាចទទួលបានចំណែកនៃទ្រព្យរួម ច្រើនជាងភាគីម្ខាងទៀត ដោយការសម្រេចសេចក្តី គឺស្ថិតទៅលើករណីជាក់ស្តែងទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រម។ ចំពោះស្ថានភាពផ្សេងទៀតក្រៅពីចំណុចខាងលើដែលប្រើពាក្យជាអាទិ៍ បានបញ្ជាក់ឲ្យឃើញថាអាចនឹងមានចំណុចផ្សេងទៀតក្រៅពីចំណុចខាងលើ ដូចនេះប្រសិនបើមាន វាគឺជាយុត្តិសាស្ត្ររបស់តុលាការដែលមើលទៅតាមរឿងក្តីនីមួយៗ។

## ៤.៣ ៖ អានុភាពចំពោះទ្រព្យដែលជាបំណុល

ក្រោយពេលលែងលះគ្នា ប្រសិនបើសហព័ទ្ធមានជាប់បំណុលក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ នោះសហព័ទ្ធត្រូវទូទាត់សងម្ចាស់បំណុល បើបំណុលនោះជាបំណុលរួម ផ្ទុយមកវិញ បើបំណុលនោះជាបំណុលផ្ទាល់ខ្លួន នោះជាកតព្វកិច្ចរបស់ជនដែលបានជំពាក់។

### ៤.៣.១ ៖ បំណុលផ្ទាល់ខ្លួន

បំណុលដែលសហព័ទ្ធម្ខាង បានជំពាក់នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ជាទូទៅជាបំណុលផ្ទាល់ខ្លួនរបស់សហព័ទ្ធ ប៉ុន្តែប្រសិនបើនៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងបានជំពាក់បំណុលដោយមិនឲ្យសហព័ទ្ធម្ខាងទៀតដឹង ហើយបានយកប្រាក់នោះមកប្រើប្រាស់

98 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣

99 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ ចំណុចខ វក្យខណ្ឌ១

100 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ ចំណុចខ វក្យខណ្ឌ២

ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដោយពុំបានប្រើប្រាស់ក្នុងទំហំនៃគ្រួសារ នោះបំណុល ដែលបានជំពាក់ជាបំណុលផ្ទាល់ខ្លួន ហើយសហព័ទ្ធម្ខាងទៀតមិនបានជាប់កតព្វកិច្ចក្នុងការសង បំណុលនោះទេ។

### ៤.៣.២ ៖ បំណុលរួម

ប្រសិនបើនៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ហើយសហព័ទ្ធមានជាប់ជំពាក់បំណុលគេ នោះវាជាបំណុលរួម ដោយសារសហព័ទ្ធទាំងសងខាងបានព្រមព្រៀងគ្នាចំពោះបំណុលនោះ ឬសហព័ទ្ធម្ខាងបានព្រមព្រៀងជាមួយម្ចាស់បំណុល ហើយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ដោយមានលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល ក្នុងករណីទាំងពីរនេះ សហព័ទ្ធទាំងសងខាងមានកាតព្វកិច្ចក្នុងការសងបំណុលទៅឲ្យម្ចាស់បំណុលពីព្រោះវាជាបំណុលរួមដែលមានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍[101]។

## ៤.៤ ៖ អានុភាពចំពោះការគ្រប់គ្រង និងបែងចែកកូន

ការលែងលះនាំឲ្យមានការបែងចែកនូវអំណាចមេបាក្នុងការគ្រប់គ្រងកូន និងការកំណត់អំពីសោហ៊ុយក្នុងការបីបាច់ថែរក្សាកូន។ បើសិនជាការលែងលះនោះគឺកើតចេញពីការព្រមព្រៀងនោះការកំណត់នូវអំណាចមេបាក៏ពុំសូវមានបញ្ហាស្មុគស្មាញដែរ។ ផ្ទុយទៅវិញបើការលែងលះនោះមិនបានកើតចេញពីការព្រមព្រៀង នោះនឹងនាំឲ្យមានការដណ្តើមនូវសិទ្ធិក្នុងការគ្រប់គ្រងកូន។ បើមានការខ្វែងគំនិតគ្នាក្នុងការកំណត់នូវអំណាចមេបា នោះឪពុក ឬម្តាយអាចដាក់ពាក្យប្តឹងទៅតុលាការដើម្បីកំណត់នូវអំណាចមេបានេះ។ ទោះបីជាតុលាមានសិទ្ធិសម្រេចនូវអំណាចមេបា ឬ ចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូនយ៉ាងណាក្តីក៏ប៉ុន្តែ "យោបល់របស់កូនត្រូវបានយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និងសភាពចាស់ទុំ"[102]ផងដែរ។

101 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៥

102 មាត្រា២២ កថាខ័ណ្ឌទី៤ នៃច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានចំណាយពេលវេលាក្នុងការសរសេរ និងចងក្រងនូវអត្ថបទសារណានេះមក យើងទាំងពីរបានកាត់សម្គាល់ថាការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺមិនមានភាពខុសគ្នាអ្វីច្រើនអំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយនឹងជនបរទេសនោះទេព្រោះអាពាហ៍ពិពាហ៍នោះប្រារព្ធនៅប្រទេសកម្ពុជាដូចនេះត្រូវគោរពទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មិនថានីតិវិធីនៃការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឬនីតិវិធីនៃការលែងលះឡើយ។

អាពាហ៍ពិពាហ៍ស្របតាមនីតិវិធីច្បាប់ គឺជាបញ្ហាដ៏សំខាន់ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវមានការយកចិត្តទុកដាក់។ ព្រោះថាអាពាហ៍ពិពាហ៍គឺជាអ្វីដែលមនុស្សទាំងអស់ត្រូវជួបប្រទះក្នុងឆាកជីវិតដោយជៀសមិនបាន អាពាហ៍ពិពាហ៍គឺជាការបង្កើតនូវចំណងនិស្ស័យរវាងបុរស និងនារី ដែលសន្យាថារស់នៅជាមួយគ្នាអស់មួយជីវិត តែបើមានបញ្ហាណាមួយកើតឡើងដូចជាការលួចក្បត់ផិត គឺមានតែច្បាប់ទេទើបអាចដោះស្រាយ និងការពារផលប្រយោជន៍សាមីជននោះបាន។

ជាក់ស្តែងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍ដែលអាចមានអានុភាពតាមផ្លូវ និងការហាមឃាត់ផ្សេងៗបង្កាកុំឲ្យមានបញ្ហានៅថ្ងៃក្រោយ។ ដូចជាការកំណត់នៅសមត្ថភាពដែលអាចរៀបអាពាហ៍ពិពាហ៍ កំណត់អំពីឆន្ទៈដើម្បីឲ្យច្បាស់ថាអាពាហ៍ពិពាហ៍នោះមិនបានកើតឡើងតាមការបង្ខិតបង្ខំ ការហាមឃាត់មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ញាតិពន្ធ និងការហាមឃាត់មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងារជ្រើសរើសគូស្រករជាដើម។ លើសពីនេះទៅទៀតច្បាប់ក៏បានកំណត់អំពីនិតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ឲ្យត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ផងដែរ ដូចជាការ ជូនដំណឹង ការដាក់ពាក្យសុំ ការប្រកាសជាសារធារណៈ ការចុះសំបុត្រអាពាហ៍ពិពាហ៍ និងជាចុងក្រោយគឺជាការចុះបញ្ជីសំបុត្រអាពាហ៍ពិពាហ៍។

ច្បាប់មិនបានការពារត្រឹមតែផលប្រយោជន៍នៅពេលដែលនៅមានចំណអាពាហ៍ពិពាហ៍តែប៉ុណ្ណោះទេ តែច្បាប់បានយកចិត្តទុកដាក់ចំពោះសហព័ទ្ធនៅក្រោយពេលការលែងលះផងដែរ។ គួយ៉ាងក្រមរដ្ឋប្បវេណីបានកំណត់បង្កាទុកមុនជាស្រេច នូវការបែងចែកទ្រព្យ ការបង់អាហារកិច្ចការកំណត់នូវអំណាចមេបា និងការប្រាស្រ័យទាក់ទងជាមួយកូនជាដើម។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានស្រាវជ្រាវនូវអត្ថបទសារណានេះកន្លងមក ធ្វើឲ្យយើងខ្ញុំបានយល់អំពីបញ្ហាជាច្រើនដែលទាក់ទងទៅនឹងចំណងអាពាហ៍ពិពាហ៍ ព្រោះការរៀបអាពាហ៍ពិពាហ៍គឺមិនត្រឹមតែផ្សារភ្ជាប់ចំណងនូវចំណងញាតិរវាងគ្នា និងគ្នានោះទេ តែសូម្បីតែសិទ្ធិ និងករណីកិច្ចមួយចំនួនត្រូវបានផ្សារភ្ជាប់ផងដែរ។ អាពាហ៍ពិពាហ៍គឺជាបញ្ហាដ៏ធំមួយដែលយើងគួរគប្បីត្រូវយកចិត្តទុកដាក់ចំពោះវា។ តែគួរឲ្យសោកស្តាយដែលប្រជាពលរដ្ឋខ្មែរយើងមួយចំនួននៅមានកង្វះខាតក្នុងការយល់ដឹងអំពីបញ្ហានេះ ជាពិសេសប្រជាពលរដ្ឋនៅតាមជនបទដែលភាគច្រើន គឺពួកគាត់គិតការរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីទំនៀមទំលាប់គឺជារឿងគ្រប់គ្រាន់ហើយ។

យើងខ្ញុំសង្កេតឃើញថា ប្រព័ន្ធនៃការផ្សព្វផ្សាយច្បាប់នៅក្នុងប្រទេសកម្ពុជាយើងនៅមានកំរិតដែលជាបញ្ហាចម្បងមួយធ្វើឲ្យប្រជាពលរដ្ឋខ្មែរមួយចំនួនខ្វះការយល់អំពីផលប៉ះពាល់ផ្សេងៗនៃការមិនគោរពច្បាប់នេះ។ នាងខ្ញុំសង្ឃឹមថា អង្គការ និងស្ថាប័នគ្រប់ជាន់ថ្នាក់ដែលមានសមត្ថកិច្ចក្នុងការចូលរួមបណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យមានការយល់ដឹងអំពីច្បាប់ឲ្យបានធំទូលាយ ដើម្បីការផ្សព្វផ្សាយច្បាប់ និង ការអនុវត្តច្បាប់ដែលទទួលបានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយនិរន្តភាព ។

យើងខ្ញុំជឿជាក់ថានៅពេលដែលពលរដ្ឋខ្មែរយើងមានចំណេះដឹងទូលំទូលាយ អំពីការរៀបអាពាហ៍ពិពាហ៍នេះនោះពួកគេនឹងគោរព និងប្រតិបត្តតាមជាក់ជាមិនខាន ព្រោះពួកបានដឹងអំពីផលប៉ះពាល់ផ្សេងៗអំពីការដែលមិនគោរពទៅនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧/០៦/០២១, ០៧ កក្កដា ២០០៦។
- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩។
- ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/១០៩៦/៣០, ២០ សីហា ១៩៩៦។
- ច្បាប់ស្តីពីអន្តោប្រវេសន៍, ២៦ សីហា ១៩៩៤។
- ច្បាប់ឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ០៨ សីហា ២០១០។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ១២ មិថុនា ២០១០។
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ២០០៩។
